# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*ប្រសិនបើអង្គជំនុំជម្រះ ឬក៏សហព្រះរាជអាជ្ញា មិនជឿនូវសេចក្តីថ្លែងការណ៍របស់ខ្ញុំទេ ខ្ញុំក៏មិនចាំបាច់ផ្តល់សក្ខីកម្មតទៅទៀតដែរ។*

- ***សាក្សី សូ សុជាតិ***[1]

## ផ្នែកទី ១៖ ទិដ្ឋភាពទូទៅ

នាសប្តាហ៍នេះ អង្គជំនុំជម្រះ បានស្តាប់ការផ្តល់សក្ខីកម្មពីសំណាក់សាក្សីចំនួនបីរូប គឺ លោក **ទន់ សឿន** លោកស្រី **សូ សុជាតិ** និងលោក **ស៊ឹម ហោ**។ កិច្ចដំណើរការនីតិវិធីបានចាប់ផ្តើមនៅថ្ងៃចន្ទ ដើម្បីស្តាប់សក្ខីកម្មពីលោក **ទន់ សឿន** ដែលជាកូនប្រសាររបស់លោក **ខៀវ សំផន** ហើយបានបន្តផ្តល់សក្ខីកម្មដោយភរិយារបស់លោក **ខៀវ សំផន** គឺលោកស្រី **សូ សុជាតិ**។ នៅថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍ សាក្សី **ស៊ឹម ហោ** បានរៀបរាប់ពីមុខងាររបស់គាត់ ដែលជាទាហានមួយរូប មុនពេលនៃការជម្លៀសទីក្រុងភ្នំពេញ ហើយនិងមុខនាទីជាកម្មករនៅក្រសួងពាណិជ្ជកម្ម ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ សក្ខីកម្មរបស់គាត់ បានផ្តោតសំខាន់ពីការកម្ចាត់របស់ខ្មែរក្រហម និងបទបញ្ជាផ្សេងៗ ដែលបានចោទប្រកាន់ថា បានធ្វើឡើងដោយលោក **ខៀវ សំផន** រហូតដល់ទីបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ។ នាសប្តាហ៍នេះ អ.វ.ត.ក បានបញ្ចប់កិច្ចប្រជុំនៃការគ្រប់គ្រងដំណើរការសវនាការជាសាធារណៈលើកដំបូងរបស់ខ្លួន ខណៈដែលភាគីទាំងអស់ បានបង្ហាញពីទឡ្ហីករណ៍ទាក់ទងនឹងសវនាការបង្ហាញឯកសារចុងក្រោយ ការសាកសួរដេញដោលជនជាប់ចោទ សារណាសង្ខេប សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ការជំនុំជម្រះនាពេលអនាគត ការជួសជុលសំណងខូចខាត និងការបកប្រែដែលនៅសេសសល់ ។

## ផ្នែកទី ២ ៖ សក្ខីកម្មសង្ខេបរបស់សាក្សី

នាសប្តាហ៍នេះ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់សាក្សី **ទន់ សឿន** សាក្សី **សូ សុជាតិ** និងសាក្សី **ស៊ឹម ហោ** ។ ទាំងសាក្សី **ទន់ សឿន** (កូនប្រសាលោក ***ខៀវ សំផន*** )និងលោកស្រី ***សូ*** **សុជាតិ** (ភរិយារបស់លោក **ខៀវ សំផន**) ត្រូវបានសាកសួរដេញដោលពីអត្តចរិតរបស់ជនជាប់ចោទ **ខៀវ សំផន**។ នៅទីបញ្ចប់ក្រៅពីមានមុខងារជាទាហានម្នាក់ ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៧៥ សាក្សី **ស៊ឹម ហោ** បានចងចាំពីការធ្វើការនៅក្នុងកងវរសេនាតូចមួយ ហើយក្រោយមកទៀត បានធ្វើជាកម្មករ ក្នុងក្រសួងពាណិជ្ជកម្ម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

### ក. សក្ខីកម្មរបស់សាក្សី ទន់ សឿន (TWC-742)

សាក្សីអត្តចរិត (សាក្សីដែលផ្តល់សក្ខីកម្មពីអត្តចរិតរបស់ជនជាប់ចោទ) **ទន់ សឿន**[2] គឺជាកូនប្រសារបស់លោក **ខៀវ សំផន**។ គាត់បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ នាព្រឹកថ្ងៃចន្ទ ដោយបានរៀបរាប់លម្អិតអំពីការសិក្សារៀនសូត្ររបស់គាត់ ក្នុងនាមជាក្មេងម្នាក់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងសកម្មភាពនានា ដែលគាត់បានធ្វើជំនួសឲ្យខ្មែរក្រហម នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០ ហើយនិងអត្តចរិតរបស់ឪពុកក្មេករបស់គាត់។

#### *ក.១. ការងារ និងការសិក្សារៀនសូត្រនៅមន្ទីរ ក-៣ និងមន្ទីរក-៥ ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ*

សាក្សីមានអាយុ ១១ឆ្នាំ ហើយបានបម្រើការងារនៅក្នុងកងកុមារខ្មែរក្រហម នៅពេលដែលគាត់ត្រូវបានគេបញ្ជូន មកកាន់ទីក្រុងភ្នំពេញដើម្បីសិក្សារៀនសូត្រ ក្នុងខែកក្កដា ឬខែសីហា ឆ្នាំ១៩៧៦។ ដំបូងឡើយសាក្សីបានស្នាក់នៅក្នុងមន្ទីរកសិកម្ម ក-៨ ហើយបានចូលរៀនភាសាខ្មែរនៅសាលាសុធារស ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ “**ពូ ភាង**” ។ ១៨ ខែក្រោយ គាត់បានប្តូរទៅកាន់មន្ទីរ ក-៣ ដើម្បីរៀនពីរបៀបវាយអត្ថបទ។

#### *ក.២. អត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន*

សាក្សីគឺកំពុងបម្រើការងារ ជាអ្នកបកស្រាយអក្សរសម្ងាត់តាមរយៈសារទូរលេខឲ្យខ្មែរក្រហម នៅពេលដែលគាត់បានជួបនឹងអនាគតឪពុកក្មេករបស់គាត់ គឺលោក **ខៀវ សំផន** ជាលើកដំបូង ក្នុងឆ្នាំ១៩៨២។ សាក្សីមិនដែលបានជួបនឹងលោក **ខៀវ សំផន** ទៀតទេ រហូតដល់ឆ្នាំ១៩៨៩ បន្ទាប់ពីពេលដែលគាត់បំពេញបេសកកម្មការទូតនៅបរទេស។ ជានិច្ចកាល សាក្សីបានធ្វើសារដោយផ្ទាល់ទៅកាន់លោក **ខៀវ សំផន** រហូតដល់ឆ្នាំ១៩៩០ នៅពេលដែលគាត់ត្រូវបានគេចាត់តាំងឲ្យធ្វើជាបេសកជនកម្ពុជាប្រជាធិបតេយ្យ នៅទីក្រុងប៉េកាំង។ បន្ទាប់ពីត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ គាត់បានប្រាប់តុលាការថា ក្នុងឆ្នាំ១៩៩៤ គាត់បានរៀបការជាមួយនឹងកូនស្រីរបស់លោក **ខៀវ សំផន** ហើយចាប់ផ្តើមរស់នៅក្នុងផ្ទះរបស់លោក **ខៀវ សំផន**។ សាក្សីបានរៀបរាប់ថា លោក **ខៀវ សំផន** ជា មនុស្ស “ស្មោះត្រង់” “សុភាពរាបសា” និងមាន “គេស្រលាញ់ចូលចិត្តច្រើន”។ គាត់បានបញ្ជាក់ថា ឪពុកក្មេករបស់គាត់រស់នៅយ៉ាងសាមញ្ញ ហើយក៏មិនលោភលន់ ឬក៏ពុករលួយ

អ្វីឡើយ។ យោងតាមសំដីរបស់សាក្សី លោក **ខៀវ សំផន** បានប្រព្រឹត្តចំពោះមនុស្សទាំងអស់យ៉ាងស្មើភាពគ្នា ហើយមិនដែលមានទស្សនៈនយោបាយ ខ្លាំងក្លាជាងបំណងប្រាថ្នារបស់គាត់ ក្នុងការបម្រើការងារ យ៉ាងស្មោះត្រង់ចំពោះចក្ខុវិស័យរបស់ព្រះអង្គម្ចាស់ **នរោត្តម សីហនុ** សម្រាប់ប្រទេសកម្ពុជានោះទេ ។

### *ក.៣. ឥរិយាបថ និងភាពគួរឲ្យជឿជាក់របស់សាក្សី*

ដំបូងឡើយ សាក្សី **ទន់ សឿន** ហាក់ដូចជាមានឆន្ទៈក្នុងការផ្តល់ព័ត៌មាន និងបើកទូលាយក្នុងការឆ្លើយតបរបស់គាត់ នៅពេលដែលមានការចោទសួរដោយមេធាវីការពារក្តីរបស់លោក **ខៀវ សំផន** ហើយហាក់ដូចជាមានបំណងយ៉ាងមោះមុត ក្នុងការពិពណ៌នាពីអត្តចរិតរបស់ឪពុកក្មេករបស់គាត់ ទៅកាន់អង្គជំនុំជម្រះ។ ទោះបីជាយ៉ាងក៏ដោយ សាក្សីបានប្រែក្លាយជាគេចវេះនូវចំណុចមួយចំនួន ក្នុងអំឡុងពេលនៃការសាកសួរដេញដោលរបស់គាត់។ ជាឧទាហរណ៍ សាក្សីមើលទៅដូចជាមានការស្ទាក់ស្ទើរក្នុងការឆ្លើយតប នៅពេលដែលសហព្រះរាជអាជ្ញា **ឃីត រេយ៍ន័រ** បានបង្ហាញសាក្សីពីសក្ខីកម្មដែលបានចោទប្រកាន់កុមារនៅសាលាសុធារស (សាលាដែលគាត់បានចូលរៀន) ត្រូវបានគេបណ្តុះបណ្តាលឲ្យបកស្រាយសារទូរលេខ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទោះបីជា សាក្សីបានឆ្លើយតបទៅនឹងសំណួរយ៉ាងនឹងនក៏ដោយ ប៉ុន្តែមានពេលខ្លះ គាត់ត្រូវបានគេកត់សម្គាល់ឃើញថា មិនបានផ្តល់នូវចម្លើយដ៏ត្រឹមត្រូវ ឬមានភាពស្ទាក់ស្ទើរមុនពេលឆ្លើយសំណួរ។

## ខ. **សក្ខីកម្មរបស់សាក្សី សូ សុជាតិ** (TCW-673)

សាក្សីអត្តចរិត **សូ សុជាតិ**[3] បានចាប់ផ្តើមផ្តល់សក្ខីកម្មរបស់គាត់ នៅថ្ងៃចន្ទ ទី១០ ខែមិថុនា ឆ្នាំ ២០១៣។ ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្ម លោកស្រីបានរៀបរាប់ពីរបៀបដែលគាត់បានចូលរួមចលនាបដិវត្តន៍ប្រឆាំងនឹងរបប **លន់ នល់** ហើយបានជួបនឹងលោក **ខៀវ សំផន** ដែលជាស្វាមីរបស់គាត់ ខណៈដែលគាត់កំពុងធ្វើការជាចុងភៅនៅ ស្ទឹង ជីនិត។ លោកស្រីក៏បានរំលឹកអំពីការសង្កេតទាំងឡាយ ដែលគាត់បានធ្វើទៅលើមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមផងដែរ។

### *ខ.១. ចលនាមុនរបបកម្ពុជាប្រជាធិបតេយ្យ*

នៅពេលលោកស្រី **សូ សុជាតិ** មានអាយុ ១៨ឆ្នាំ គាត់បានឈប់រៀន ដើម្បីជួយគ្រួសាររបស់គាត់ធ្វើស្រែចម្ការ។ នៅពេលនោះ លោកស្រីបានបញ្ចប់ការសិក្សាត្រឹមថ្នាក់ទី៥។ បន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ លោកស្រីបានចូលរួមចលនាប្រឆាំង ហើយត្រូវបានគេដាក់នៅក្នុងក្រុមស្ត្រី ជាកន្លែងដែលលោកស្រីធ្វើជាគ្រូពេទ្យប្រចាំភូមិ ដោយព្យាបាលប្រជាជនដែលឆ្លងជំងឺគ្រុនចាញ់ និងជំងឺរាគ។ នៅពាក់កណ្តាលឆ្នាំ១៩៧១ គាត់បានចូលរួមវគ្គសិក្សារៀនសូត្រជាច្រើន ដែលបានបង្រៀនដោយស្ត្រីម្នាក់ឈ្មោះ **ស៊ិន យិម**។ លោកស្រីបានប្រាប់តុលាការថា វគ្គសិក្សារៀនសូត្រទាំងនោះ បានជំរុញទឹកចិត្តលោកស្រីឲ្យទៅរស់នៅក្នុងព្រៃជាមួយនឹងចលនាប្រឆាំង។ បន្ទាប់ពីបានធ្វើដំណើរទៅកាន់ ស្ទឹងជីនិត លោកស្រីបានរំលឹកថា គាត់ត្រូវបានចែចង់ដោយអនាគតស្វាមីរបស់គាត់ គឺលោក **ខៀវ សំផន** ខណៈដែលលោកស្រីកំពុងបម្រើការជាចុងភៅ នៅទីនោះ។ លោកស្រី **សូ សុជាតិ** បានរៀបការជាមួយលោក **ខៀវ សំផន** ដូចជានៅក្នុងឆ្នាំ១៩៧២ ហើយបានរំលឹកថា បន្ទាប់ពីបានរៀបការរួច ពួកគេបានផ្លាស់ប្តូរទីតាំងជារៀងរាល់ខែ ដើម្បីជៀសវាងពីការតាមដាន។

គាត់បានប្រាប់តុលាការថា ពួកគេបានស្នាក់នៅមន្ទីរ ប-១៧ បន្ទាប់មកមន្ទីរ ប-២០ ហើយពីរ ឬបីខែក្រោយមក បានប្តូរទៅកាន់មន្ទីរមៀក មុនពេលប្តូរទៅកាន់មន្ទីរ ក-១ ក្នុងឆ្នាំ១៩៧៥។

### *ខ.២. ការរៀបការជាមួយលោក ខៀវ សំផន*

មានពេលមួយ បន្ទាប់ពីទៅដល់ស្ទឹងជីនិត លោកស្រី **សូ សុជាតិ** បានជួបនឹងលោក **ខៀវ សំផន**។ នៅពេលនោះ លោកស្រីគ្រាន់តែបានស្គាល់លោក **ខៀវ សំផន** ដែលមានឈ្មោះថា "**ហែម**" ឬ "**បងហែម**"។ ពីរ ឬបីខែក្រោយមក លោក **ខៀវ សំផន** បានសុំលោកស្រី **សូ សុជាតិ** រៀបការ តាមរយៈស្រ្តីម្នាក់ឈ្មោះ **យឹម**។ សាក្សីបានប្រាប់តុលាការថា លោកស្រីមិនបានឆ្លើយយល់ព្រមភ្លាមៗនោះទេ ពីព្រោះលោកស្រីមិនទាន់ស្គាល់លោក **ខៀវ សំផន** ច្បាស់នៅឡើយ ហើយលោកស្រីបានងឿងឆ្ងល់ថា ហេតុអ្វីបានជាគាត់នៅលីវរហូតដល់មានវ័យចំណាស់យ៉ាងហ្នឹង។ **យឹម** បានប្រាប់លោកស្រីថា លោក **ខៀវ សំផន** ជាបញ្ញវន្ត និងជាមនុស្សស្អាតស្អំមួយរូប។ ពីរ ឬបីឆ្នាំក្រោយមក ដោយសារគ្មានចម្លើយពីលោកស្រី **សូ សុជាតិ** លោក **ខៀវ សំផន** បានសុំឲ្យ **យឹម** បញ្ជាក់សំណើសុំរៀបការសាជាថ្មីម្តងទៀត។ ពេលនោះ លោកស្រី **សូ សុជាតិ** ក៏បានសម្រេចចិត្តរៀបការជាមួយលោក **ខៀវ សំផន** ហើយក៏ជឿជាក់ថាគាត់ជាមនុស្សប្រុស "ដ៏ត្រឹមត្រូវ" ម្នាក់សម្រាប់លោកស្រី។ លោកស្រី បានពិពណ៌នាពីពិធីរៀបការ ដែលលោកស្រីបានសន្មតថាបានប្រារព្ធធ្វើឡើង ក្នុងឆ្នាំ១៩៧២ ថាមានលក្ខណៈ "សប្បាយរីករាយ" ទោះបីជាវាមិន "អធិកអធម" ក៏ដោយ។

### *ខ.៣. បទពិសោធន៍នៅមន្ទីរ ក-១ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*

សាក្សីបានថ្លែងថា លោកស្រី និងលោក **ខៀវ សំផន** បានប្តូរទៅកាន់មន្ទីរ ក-១ (នៅទល់មុខទន្លេបាសាក់) នៅពាក់កណ្តាលឆ្នាំ១៩៧៥ ហើយបានរស់នៅទីនោះរហូតដល់ឆ្នាំ១៩៧៦។ ទោះបីជា មន្ទីរ ក-១ ត្រូវបានគេប្រើប្រាស់ជាផ្ទះរបស់មេដឹកនាំកំពូលៗក៏ដោយ ប៉ុន្តែលោកស្រី **សូ សុជាតិ** បានប្រាប់តុលាការថា ស្ថានភាពរស់នៅនៅទីនោះ មិនមានអ្វីល្អប្រសើរជាងពេលដែលពួកគាត់បានរស់នៅក្នុងព្រៃនោះទេ។ លោកស្រីបានរំលឹកអំពីរបៀប ដែលសមាជិកគ្រួសារចំនួនបីរូប បានដេកផ្ទាល់នឹងដីក្នុងបន្ទប់តែមួយ ដោយយកខោអាវធ្វើជាខ្នើយ។ សាក្សីបានធ្វើការជាចុងភៅនៅមន្ទីរ ក-១ ហើយបាននិយាយថា ម្ហូបអាហារគឺ "មិនសម្បូរ" នោះទេ។ លោកស្រីបានប្រាប់តុលាការពីវិធី ដែលលោកស្រីចម្អិនអាហារនៅឯមន្ទីរ ក-១ សម្រាប់មេដឹកនាំជាន់ខ្ពស់ រួមមានលោក **ប៉ុល ពត** លោក **នួន ជា** លោក **អៀង សារី** លោក **សុន សេន** លោក **ខៀវ** និងលោក **វន វេត**។ ស្ថិតនៅក្រោមការសាកសួរដេញដោលរបស់សហព្រះរាជអាជ្ញា សាក្សីបានសារភាពថា ជាការពិតណាស់ លោកស្រីទទួលបន្ទុកការងារផ្ទះបាយ នៅមន្ទីរ ក-១ បើទោះបីជាដំបូងឡើយ លោកស្រីបានបដិសេធក៏ដោយ។ លោកស្រីបានប្រាប់តុលាការថា មានពេលមួយ នៅដើមឆ្នាំ១៩៧៦ មេដឹកនាំជាច្រើនរូប រួមទាំងស្វាមីរបស់គាត់ផងដែរ បានប្តូរពីមន្ទីរ ក-១ ទៅកាន់មន្ទីរ ក-៣។ សហព្រះរាជអាជ្ញា ដែលបានចោទប្រកាន់លោកស្រីថា "កំពុងបង្កើត" សាច់រឿង បានធ្វើការប្រឆាំងយ៉ាងខ្លាំងក្លាចំពោះការលើកឡើងនេះ។ លោកស្រីបានអះអាងថា លោកស្រីមិនបានដឹងរឿងអីទេ ពីព្រោះតែមានផ្ទៃពោះ ហើយពីរ ឬបីខែបន្ទាប់ពីសម្រាលកូនទីពីររួច ក៏បានធ្វើដំណើរទៅកាន់មន្ទីរ ក-៣ ជាកន្លែងដែលលោកស្រីបានរស់នៅជាមួយក្រុមគ្រួសារ រហូតដល់ដួលរលំទីក្រុងភ្នំពេញ។

## ខ.៤. បទពិសោធន៍នៅមន្ទីរ ក-៣ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

លោកស្រីបានប្រាប់តុលាការថា ពេលដែលលោកស្រីបានទៅដល់មន្ទីរ ក-៣ ប្រហែលជាក្នុងឆ្នាំ ១៩៧៦ លោក **ខៀវ សំផន** កំពុងរស់នៅក្នុងផ្ទះឈើមួយខ្នង ក្នុងស្ថានភាពរស់នៅដែល "មិនសមជាមនុស្ស"។ លោកស្រី **សូ សុជាតិ** បានរំលឹកពីការរស់នៅជាមួយភរិយារបស់លោក **នួន ជា** រហូតដល់ **ប៉ុល ពត** បានបញ្ជាឲ្យគេសាងសង់ផ្ទះថ្មីមួយ សម្រាប់គ្រួសាររបស់ពួកគេ។ លោកស្រីបានបន្ថែមថា ទោះបីជាស្ថានភាពរស់នៅក្នុងមន្ទីរ ក-៣ មានលក្ខណៈល្អប្រសើរជាងនៅមន្ទីរ ក-១ ក៏ដោយ ប៉ុន្តែកង្វះខាតស្បៀងអាហារនៅតែបន្តកើតមាន ហើយពេលខ្លះ ពួកគាត់មិនមានអាហារគ្រប់គ្រាន់សម្រាប់បរិភោគទៀតផង។ សាក្សីបានបញ្ជាក់ថា ភារកិច្ចចម្បងរបស់គាត់នៅមន្ទីរ ក-៣ គឺចម្អិនអាហារ ធ្វើកិច្ចការផ្ទះ និងមើលថែរក្សាកូនស្រីរបស់គាត់។ លោកស្រីបានប្រាប់តុលាការអំពីរបៀប ដែលកូនប្រុសរបស់លោកស្រី ត្រូវបានគេបញ្ជូនទៅកងកុមារ នៅពេលដែលគាត់មានអាយុត្រឹមតែ បីឆ្នាំ ហើយបើទោះបីជា ទាំងលោកស្រី និងលោក **ខៀវ សំផន** មិនពេញចិត្តនឹងស្ថានភាពបែបនេះ ក៏ពួកគាត់ពុំដែលត្អូញត្អែរជាផ្លូវការណាមួយដែរ។ បន្ទាប់ពីបានរស់នៅក្នុងមន្ទីរ ក-៣ អស់ រយៈពេលបួន ទៅប្រាំខែមក សាក្សីបានបញ្ជាក់ថា មេដឹកនាំជាន់ខ្ពស់ ជាគោលការណ៍គឺមាន **ប៉ុល ពត** លោកនួន **ជា** លោក **អៀង សារី** លោក **វន វេត** និងលោក **សុន សេន** បានចាកចេញពីមន្ទីរ ក-៣ ទៅកាន់មន្ទីររបស់ពួកគេជាបន្តបន្ទាប់។ មានតែលោក **ខៀវ សំផន** ទេ ដែលបន្តរស់នៅក្នុងមន្ទីរ ក-៣ ហើយគាត់បានចាកចេញទៅសួរសុខទុក្ខនៅមន្ទីរ ក-១ ម្តងម្កាល។ សាក្សីបានប្រាប់តុលាការថា លោក **នួន ជា** ក៏មកសួរសុខទុក្ខនៅមន្ទីរ ក-៣ ម្តងម្កាលដែរ។

## ខ.៥. ការយល់ដឹងពីការចាប់ខ្លួន និងការកម្ចាត់

លោកស្រី **សូ សុជាតិ** បានបដិសេធមិនបានដឹងអំពីការចាប់ខ្លួន ឬការកម្ចាត់នានា ខណៈដែលលោកស្រីធ្វើការនៅមន្ទីរ ក-១ និងមន្ទីរ ក-៣។ សាក្សីរូបនេះបាននិយាយថា ពេលនៅមន្ទីរ ក-១ ឬមន្ទីរ ក-៣ គាត់មិនធ្លាប់ឆ្លងកាត់បរិយាកាសដ៏គួរឲ្យភ័យខ្លាចនោះទេ។ លោកស្រីក៏បានបដិសេធផងដែរថា មិនធ្លាប់បានចូលរួមវគ្គសិក្សារៀនសូត្រណាមួយឡើយ ហើយក៏ប្រាប់តុលាការដែរថា លោកស្រីមិនធ្លាប់និយាយជាមួយស្វាមីរបស់លោកស្រីអំពីបញ្ហានយោបាយ ឬមុខងាររបស់គាត់នោះឡើយ។ ទោះបីជាយ៉ាងណា លោកស្រីបានថ្លែងប្រាប់តុលាការថា លោកស្រីធ្លាប់បានឮថា ពួកគេគឺតម្រូវឲ្យមានការប្រុងប្រយ័ត្នខ្ពស់ទាក់ទិននឹងរឿងសត្រូវ ប៉ុន្តែលោកស្រីបានបដិសេធមិនបានដឹងរឿងរ៉ាវអ្វីផ្សេងទៀតទេ។ នៅពេលត្រូវបានសាកសួរជាពិសេសទាក់ទងទៅនឹង "**ឌឿន**" សាក្សីបានបញ្ជាក់ថា លោកស្រីតែងតែចម្អិនអាហារឲ្យ **ឌឿន** ជាអ្នកដែលហូបក្រោយគេ ប៉ុន្តែក្រោយមក គាត់បានឈប់មកមួយរយៈពេល។ លោកស្រីបានថ្លែងថា លោកស្រីមិនធ្លាប់ពិភាក្សាពីការបាត់ខ្លួនរបស់ **ឌឿន** ជាមួយនឹងស្វាមីលោកស្រីទេ ប៉ុន្តែក្រោយមក លោកស្រីបានសារភាពថា លោកស្រីបាននិយាយ បន្ទាប់ពីសហព្រះរាជអាជ្ញា បានបង្ហាញលោកស្រីនូវអត្ថបទខ្លីៗ ដែលដកស្រង់ពីសៀវភៅរបស់លោក **ខៀវ សំផន** ដោយបានបង្ហាញថា ពួកគាត់ពិតជាបាននិយាយគ្នាពីរឿងបាត់ខ្លួនរបស់ **ឌឿន** មែន។ ទាក់ទិននឹងការចាប់ខ្លួនសមាជិកគ្រួសាររបស់លោកស្រី រួមមានឪពុកម្តាយ បងប្រុស និងបងប្អូនជីដូនមួយ សាក្សីបានប្រាប់តុលាការថា លោកស្រីគ្រាន់តែបានដឹងថា ពួកគេត្រូវបានគេចាប់ខ្លួន នៅពេលដែលពួកគេត្រូវបានដោះលែងក្នុងឆ្នាំ១៩៧៨ ។

## ខ.៦. ការដឹងអំពីតួនាទីរបស់លោក ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

លោកស្រី **សូ សុជាតិ** បានបដិសេធជាប់ជានិច្ចថា ពុំបានដឹងពីសកម្មភាពរបស់ស្វាមីលោកស្រី ក្នុងរបបខ្មែរក្រហមទេ ដោយបានបញ្ជាក់ថា លោកស្រីគ្រាន់តែជាចុងភៅម្នាក់ ហើយវាក៏មិនមែនជារឿងល្អទេសម្រាប់ភរិយា ដែលជជីកសួរដេញដោលអំពីសកម្មភាពរបស់ស្វាមីនោះ។ លោកស្រីបានអះអាងថា វាមិនមែនរហូតដល់ឆ្នាំ១៩៧៣ ទេ ដែលលោកស្រីបានស្គាល់ពីឈ្មោះពិតប្រាកដរបស់ស្វាមីលោកស្រី គឺឈ្មោះ **ខៀវ សំផន**។ ជុំវិញការផ្តល់សក្ខីកម្មរបស់លោកស្រីទាំងមូល លោកស្រីនៅតែបន្តរក្សាជំហរថា លោកស្រីមិនដែលគិតថា ស្វាមីរបស់លោកស្រីជាឥស្សរជនសំខាន់ក្នុងជួរមេដឹកនាំខ្មែរក្រហមនោះទេ។ លោកស្រីបានប្រាប់ត្រឹមតែការយល់ដឹងដែលមានកម្រិតមួយ ពីការហូបអាហារពេលល្ងាចរបស់ស្វាមីលោកស្រី ជាមួយសមមិត្តមេដឹកនាំខ្មែរក្រហម ហើយបានបញ្ជាក់ថា មិនបានដឹងពីពិធីជប់លៀងជាច្រើនដងទៀត ដែលបានរៀបចំឡើងដោយខ្មែរក្រហមឡើយ ទោះបីជាស្វាមីរបស់លោកស្រីមានវត្តមាននៅទីនោះក៏ដោយ។ លោកស្រីក៏បានអះអាងថា លោកស្រីមិនបានដឹងថា ប្អូនស្រីរបស់លោកស្រី ត្រូវបានដោះលែងពីគុកនៅសៀមរាប ដោយសារតែឥទ្ធិពលរបស់ស្វាមីលោកស្រីនោះទេ។

លោកស្រី **សូ សុជាតិ** បានផ្តល់សក្ខីកម្មថា ទោះបីជា លោក **ខៀវ សំផន** បានចាកចេញទៅធ្វើការជារៀងរាល់ថ្ងៃក៏ដោយ ប៉ុន្តែលោកស្រីមិនបានដឹងអ្វីទាំងអស់ អំពីផលប៉ះពាល់ដែលចេញពីការងាររបស់ស្វាមីលោកស្រី។ នៅពេលដែលពួកគេបានស្នាក់នៅមន្ទីរ ក-៣ លោកស្រីបានរំលឹកថា មានពេលខ្លះ លោក **ខៀវ សំផន** បានយកកូនស្រីរបស់ពួកគេ ដែលមានអាយុប្រហែលមួយខួប ទៅធ្វើការជាមួយ។ សាក្សីបានបញ្ជាក់ថា កូនស្រីគាត់បានធ្វើត្រាប់តាមលោក **ខៀវ សំផន** និយាយទូរសព្ទ បន្ទាប់ពីទៅធ្វើការជាមួយគាត់ ដែលភ្លាមនោះ លោកស្រីបានសួរពីលក្ខណៈការងាររបស់គាត់។ ស្វាមីលោកស្រី បានប្រាប់ថា ការងាររបស់គាត់គឺបញ្ជាឲ្យគេរៀបចំទំនិញសម្រាប់មូលដ្ឋាន ប៉ុន្តែឃ្លាំងស្តុកទំនិញស្ថិតនៅកន្លែងផ្សេងពីនេះ។ លោកស្រីបានបញ្ជាក់ផងដែរថា ស្វាមីលោកស្រីមិនធ្លាប់និយាយអ្វីទាក់ទងទៅនឹង "ការបាត់ខ្លួន" របស់មេដឹកនាំបក្សនោះទេ។ លោកស្រីក៏បានបដិសេធផងដែរ ពីការបានដឹងអំពីបទសម្ភាសន៍របស់ស្វាមីលោកស្រី ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត មុនពេលមានសវនាការបច្ចុប្បន្ន។

## ខ.៧. អត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន

លោកស្រី **សូ សុជាតិ** បានបង្ហាញនូវការកោតសរសើរចំពោះលោក **ខៀវ សំផន** ដែលលោកស្រីចាត់ទុកថា ជាមនុស្សអត់ធ្មត់ សុភាពរាបសា និងជាមនុស្សចេះដាក់ខ្លួន។ លោកស្រីបានបញ្ជាក់ថា ៖

> ស្វាមីខ្ញុំ គឺជាមនុស្សស្មោះត្រង់ម្នាក់ ហើយខ្ញុំជឿទុកចិត្តគាត់ ទោះជាមានការចោទប្រកាន់ប្រឆាំងនឹងគាត់ក៏ដោយ។ ខ្ញុំសូមប្រកាសយ៉ាងឱឡារិក ក្នុងឋានៈជាភរិយារបស់គាត់ថា អ្វីដែលខ្ញុំឃើញគឺខុសពីអ្វីដែលអ្នកដទៃអាចឃើញ... ប្រសិនបើស្វាមីរបស់ខ្ញុំ ត្រូវគេប្រៀបធៀបទៅនឹងមនុស្សផ្សេងនោះ ចំពោះខ្ញុំ គាត់គឺជាមនុស្សដែលមានគុណធម៌ និងសីលធម៌ខ្ពស់បំផុត។ គាត់មិនដែលធ្វើឲ្យខ្ញុំរកាំចិត្តដោយទង្វើណាមួយឡើយ ហើយគាត់ជាមនុស្សស្មោះត្រង់បំផុត។ គាត់មិនមែនជាឃាតករទេ គាត់មិនមែនជាមនុស្សដែលបានបញ្ជាឲ្យមានការចាប់ខ្លួនដែរ ហើយទាំងនេះគឺជាអ្វីដែលខ្ញុំបានឃើញដោយភ្នែកខ្ញុំផ្ទាល់។

ជុំវិញការផ្តល់សក្ខីកម្មរបស់គាត់ទាំងអស់ លោកស្រីបានលើកឡើងនូវឧទាហរណ៍ជាច្រើន ដែលលោកស្រីយល់ឃើញថា បានបង្ហាញពីអត្តចរិតដ៏ល្អរបស់លោក **ខៀវ សំផន** រួមមាន គាត់បើកឡាន *ឡាំប្រិតា* (Lambretta) ខណៈដែលមេដឹកនាំដទៃទៀត មានឡានថ្លៃ និងទំនើបៗ។ លោកស្រីក៏បានប្រាប់តុលាការពីរបៀបដែល ក្រោយពីត្រឡប់មកពីប្រទេសចិនវិញ លោក **ខៀវ សំផន** បានចំណាយពេលប្រហែលមួយខែ ដើម្បីមើលថែរក្សាលោកស្រី បន្ទាប់ពីគាត់បានសម្រាលកូនទីមួយរួច។ លោកស្រី **សូ សុជាតិ** បានរំលឹកថា លោក **ខៀវ សំផន** គឺមានការព្រួយបារម្ភពីសុខភាពរបស់គាត់យ៉ាងខ្លាំង ហើយបានជួយបោកក្រណាត់កន្ទប យកម្ហូបអាហារ និងទឹកឲ្យគាត់ទៀតផង។

### *ខ.៨. ឥរិយាបថ និងភាពគួរឲ្យជឿជាក់របស់សាក្សី*

សក្ខីកម្មរបស់លោកស្រី **សូ សុជាតិ** គឺមានលក្ខណៈរំជួលចិត្ត ហើយមានពេលជាច្រើន ក្នុងរយៈពេលពីរថ្ងៃនៃការផ្តល់សក្ខីកម្មរបស់គាត់ ទាំងសាក្សី និងលោក **ខៀវ សំផន** បានបង្ហូរទឹកភ្នែក។ សាក្សីបានផ្តល់សេចក្តីថ្លែងការណ៍ដែលមិនស៊ីគ្នាជាច្រើនសា ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មទាំងមូលរបស់គាត់ ជាពិសេស ក្នុងពេលនៃការសាកសួរដេញដោលពីសំណាក់ព្រះរាជអាជ្ញា **វេយ័ន់រ**។ សហព្រះរាជអាជ្ញា **វេយ័ន់រ** បានវាយប្រហារពីភាពគួរឲ្យជឿជាក់របស់សាក្សី ដោយបង្ហាញលោកស្រី **សូ សុជាតិ** នូវអត្ថបទដកស្រង់ពីសៀវភៅរបស់លោក **ខៀវ សំផន** ដែលផ្ទុយទៅនឹងសេចក្តីថ្លែងការណ៍មុនៗ មួយចំនួន ដែលអ្នកស្រីបានធ្វើឡើង។[4] មានពេលមួយ ព្រះរាជអាជ្ញា **វេយ័ន់រ** បានចោទប្រកាន់លោកស្រីថា កំពុងតែ "និយាយកុហក"។ អ្នកឃ្លាំមើលសវនាការ បានកត់សម្គាល់ឃើញថា បញ្ហាបកប្រែ អាចចូលរួមចំណែកខ្លះៗ ទាក់ទិននឹងភាពមិនស្របគ្នានៅក្នុងសក្ខីកម្មរបស់គាត់ ព្រមទាំងបញ្ហាមួយ ដែលបានលើកឡើងដោយមេធាវី **គង់ សំអុន** ក្នុងអំឡុងពេលនៃកិច្ចដំណើរការ នីតិវិធី (សូមមើល ផ្នែកទី ៣.ច)។ នៅពេលត្រូវបានសាកសួរដេញដោលដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **គ្រីស្ទីន ម៉ាទីណូ** សាក្សីបានបន្តបដិសេធបានដឹងអំពីសកម្មភាពនានា របស់ស្វាមីលោកស្រី ក្នុងរបបខ្មែរក្រហម។ ទាំងនេះ បានបង្កើនឲ្យមានភាពជឿជាក់កាន់តែតិចឡើង ជាពិសេសនៅពេលដែលគាត់បានរក្សាជំហរថា បើទោះបីជា លោកស្រីបានដឹងថាមានមនុស្សបានស្លាប់នៅក្នុងរបបខ្មែរក្រហម ប៉ុន្តែលោកស្រីគ្រាន់តែបានដឹងពីការសម្លាប់ទាំងនោះនៅពេលក្រោយ ហើយសូម្បីតែពេលឥឡូវនេះ ៣០ឆ្នាំមកហើយ លោកស្រីនៅតែមិនបានដឹងថា តើស្វាមីរបស់គាត់មានតួនាទីអ្វី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មានពេលមួយនៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់គាត់ សាក្សីបានលាតត្រដាងឈ្មោះសាក្សីនាពេលអនាគតមួយរូប បើទោះបីជាផ្ទុយពីការព្រមានពីសំណាក់ចៅក្រម **ឡាវែន** ក្នុងការមិនអនុញ្ញាតឲ្យបង្ហាញឈ្មោះសាក្សីក៏ដោយ។

## គ. សក្ខីកម្មរបស់សាក្សី ស៊ឹម ហោ (TCW-648)

សាក្សី **ស៊ឹម ហោ**[5] គឺជាមេភូមិម្នាក់ មកពីខេត្តកំពង់ធំ ត្រូវបានកោះហៅដោយសហព្រះរាជអាជ្ញា ឲ្យមកផ្តល់សក្ខីកម្មរបស់គាត់ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣។ ក្នុងរយៈពេលលើសពីពីរថ្ងៃ គាត់បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ អំពីជីវប្រវត្តិ និងការងាររបស់គាត់ជាមួយខ្មែរក្រហម ការកំណត់គោលដៅទៅលើទាហាន **លន់ នល់** ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ ជំនួបរវាងបុគ្គលិកមួយ

ចំនួននឹងលោក **ខៀវ សំផន** ហើយនិងការបាត់ខ្លួនរបស់បុគ្គលិកពីក្រសួងពាណិជ្ជកម្ម នៃរបបកម្ពុជាប្រជាធិបតេយ្យ។

### *គ.១. ជីវប្រវត្តិ និងតួនាទីរបស់សាក្សី*

ក្នុងនាមជាបុរសវ័យក្មេងម្នាក់ **ស៊ឹម ហោ** បានប្រាប់តុលាការពីរបៀបដែលគាត់បានចុះឈ្មោះក្នុងកងវរសេនាតូចលេខ ៧០៩ នៅភូមិភាគឧត្តរ គឺដោយសារតែគាត់មានកំហឹងនឹងការទម្លាក់គ្រាប់បែករបស់អាមេរិច និងការឈ្លានពានរបស់វៀតណាម។ កងពលរបស់គាត់ ជាផ្នែកមួយនៃកងទ័ពបដិវត្តន៍ពាក់ព័ន្ធនឹងយុទ្ធនាការ ដែលដណ្តើមយកទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ដោយសារខ្មែរក្រហមទទួលបានជ័យជម្នះ គេលែងត្រូវការកងទ័ពទៀតហើយ ដូច្នេះកងពលរបស់គាត់ ត្រូវបានគេប្តូរទៅជាកងវរសេនាតូចកម្មករវិញ ដែលស្ថិតនៅក្រោមក្រសួងពាណិជ្ជកម្ម នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ស្ថិតនៅក្នុងកងពលនេះ សាក្សីបានធ្វើការជាកម្មករផែកប៉ាល់ នៅខេត្តកំពង់សោម (ខេត្តព្រះសីហនុ បច្ចុប្បន្ន) ដោយជញ្ជូនចេញនូវឧបករណ៍កសិកម្ម និងសម្ភារផ្គត់ផ្គង់ ចេញពីកប៉ាល់របស់ពាណិជ្ជករជនជាតិចិន ហើយជញ្ជូនចូលវិញនូវកៅស៊ូ កប្បាស ស្រូវ និងទំនិញផ្សេងៗទៀតសម្រាប់នាំចេញ។ ក្រោយពីបានរស់នៅក្នុងខេត្តកំពង់សោម អស់រយៈពេលមួយឆ្នាំមក គាត់ត្រូវបានគេបញ្ជូនទៅកាន់ទីក្រុងភ្នំពេញ ជាកន្លែងដែលគាត់ជញ្ជូនចេញនូវសម្ភារផ្គត់ផ្គង់ នៅក្រុងតាខ្មៅ។

### *គ.២. ការកម្ចាត់ទាហាន លន់ នល់*

មុនពេលនៃការដួលរលំរបបខ្មែរក្រហម **ស៊ឹម ហោ** បានផ្តល់សក្ខីកម្មថា កងពលរបស់គាត់ចាប់បានទាហាន **លន់ នល់** ត្រឹមតែម្នាក់ ឬពីរនាក់ប៉ុណ្ណោះ។ គាត់បានដឹងថា ពួកគេត្រូវបានចាប់ខ្លួន ប៉ុន្តែគាត់មិនបានដឹងថាមានរឿងអ្វីកើតឡើង បន្ទាប់ពីការចាប់ខ្លួនពួកគេនោះទេ។ គាត់មិនធ្លាប់បានឃើញការសម្លាប់ណាមួយធ្វើចំពោះទាហានទាំងនោះទេ។ កងវរសេនាតូចលេខ ៧០៩ បានមកដល់ជាយទីក្រុងភ្នំពេញ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥។ ដោយបានឈប់សម្រាកជាបណ្តោះអាសន្ននៅផ្លូវប្រសព្វគ្នា ដែលមានចម្ងាយប្រហែល ៦គីឡូម៉ែត ពីទីក្រុង **ស៊ឹម ហោ** មិនបានឃើញដោយផ្ទាល់ភ្នែកនូវការជម្លៀសទ្រង់ទ្រាយធំ ដែលគាត់បានបញ្ជាក់ថា បានកើតឡើងមុននោះបន្តិចនោះទេ។ ប៉ុន្តែ មានជនភៀសខ្លួនជាច្រើន នៅតែបន្តចាកចេញពីទីក្រុង។ ផ្ទុយពីអតីតទាហានខ្មែរក្រហមដទៃទៀត ដែលបានផ្តល់សក្ខីកម្មថា ពួកគេត្រូវបានគេបញ្ជាឲ្យស្វែងរកទាហាន **លន់ នល់** និងមន្ត្រីរាជការពីក្នុងចំណោមមនុស្សដ៏ច្រើន ដែលកំពុងតែចាកចេញពីទីក្រុង **ស៊ឹម ហោ** បាននិយាយថា គាត់មិនបានទទួលបញ្ជាបែបនឹងទេ។ ប្រហែលមួយឆ្នាំក្រោយពីការដួលរលំទីក្រុងភ្នំពេញ ខណៈមានមុខងារជាកម្មករនៅទីក្រុងភ្នំពេញ **ស៊ឹម ហោ** បានផ្តល់សក្ខីកម្មថា គាត់ធ្វើការជាមួយកុមារមួយក្រុម ដែលជាកូនប្រុស និងកូនស្រីរបស់អតីតមន្ត្រីរដ្ឋាភិបាល **លន់ នល់**។

### *គ.៣. ការយល់ដឹងពីតួនាទីរបស់លោក ខៀវ សំផន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*

អំឡុងពេលនៃការសាកសួរដោយមេធាវីការពារក្តី **អាកទួរ វ៉េកគែន** សាក្សីបានប្រាប់តុលាការថា ប្រហែលជាក្នុងឆ្នាំ១៩៧៩ ខណៈដែលគាត់បានបម្រើការជាកម្មករ នៅក្នុងក្រសួងពាណិជ្ជកម្ម គាត់បានចូលរួមកិច្ចប្រជុំ ដែលបានដឹកនាំដោយលោក **ខៀវ សំផន** ហើយមានការចូលរួមពីប្រជាជនមកពីក្រសួងផ្សេងៗ

ប្រហែលជា ១០០នាក់។ ក្នុងអំឡុងពេលនៃកិច្ចប្រជុំ លោក **ខៀវ សំផន** បានប្រាប់កងពលឲ្យជីកផ្លៀល និងត្រៀមខ្លួនជាស្រេចដើម្បីតតាំងនឹងខ្មាំងនៅទីក្រុងភ្នំពេញ និងការភ័យខ្លាចពីការវាយប្រហារមួយរបស់ជប៉ុនដែលអាចនឹងកើតឡើងក្នុងពេលឆាប់ៗ។ សេចក្តីអធិប្បាយពីសំណាក់មេធាវីការពារក្តី បានស្នើនូវបញ្ហាដែលត្រូវបានលើកឡើងក្នុងគោលបំណងចង់បង្ហាញថា លោក **ខៀវ សំផន** បានចេញបញ្ជាឲ្យការពារកម្មករដោយខ្លួនពួកគេផ្ទាល់។

### *គ.៤. ការចាប់ខ្លួន និងការបាត់ខ្លួនកម្មាភិបាល*

សាក្សីបានប្រាប់តុលាការថា គាត់បានកត់សម្គាល់ឃើញថា មានការចាប់ខ្លួន និងការបាត់ខ្លួនជាច្រើនពេលកំពុងធ្វើការនៅក្នុងក្រសួងពាណិជ្ជកម្ម ដោយបានបន្ថែមថា ការចាប់ខ្លួនបានរួមចំណែកក្នុងការបង្កើត "បរិយាកាសភ័យខ្លាច" នៅក្នុងមន្ទីរ។ ក្នុងអំឡុងពេលនៃការប្រជុំ **ស៊ឹម ហោ** បានឮគេប្រកាសថា សមមិត្តកម្មករ **កុយ ធួន** គឺជាគិញរបស់ សេ.អ៊ី.អា។ ក្រោយមក លោក **កុយ ធួន** ត្រូវបានគេចាប់ខ្លួន ហើយគាត់បានកត់សម្គាល់ថា ការចាប់ខ្លួនផ្សេងៗទៀត ក៏ត្រូវបានគេធ្វើចំពោះថ្នាក់ក្រោមដើម្បីខិតខំប្រឹងប្រែងក្នុងការកម្ទេច "បណ្តាញក្បត់" ប៉ុន្តែការចាប់ខ្លួនទាំងនោះ មិនត្រូវបានគេប្រកាសឲ្យដឹងទេ។ សាក្សីក៏បានប្រាប់តុលាការផងដែរអំពីការចាប់ខ្លួនដទៃទៀត រាប់បញ្ចូលទាំងការចាប់ខ្លួនរបស់មេគាត់ ឈ្មោះ **ជា** ដែលត្រូវបានគេចាប់ខ្លួនដោយការភ្ជង់កាំភ្លើង។ ក្រោយមកទៀត សាក្សីបានដឹងពីមិត្តម្នាក់ថា មានផែនការក្នុងការចាប់ខ្លួនរបស់គាត់ផងដែរ។ ដើម្បីគេចពីការចាប់ខ្លួននេះ គាត់បានទៅជួបមេរបស់គាត់ ហើយបានប្រាប់ថា រូបគាត់មិនមែនជាខ្មាំងទេ ហើយបាននិយាយជាមួយគាត់អំពីសារសំខាន់នៃការគោរពតាមបញ្ជារបស់បក្ស។ មេរបស់គាត់ត្រូវបានគេចាប់ខ្លួននៅថ្ងៃបន្ទាប់។

### *គ.៥. ឥរិយាបថ និងភាពគួរឲ្យជឿជាក់របស់សាក្សី*

សាក្សី **ស៊ឹម ហោ** ហាក់ដូចជាឆ្លើយតបដោយមិនលាក់លៀមចំពោះសំណួរទាំងអស់ ដែលបានសួរទៅកាន់គាត់។ នៅពេលសួរឲ្យបញ្ជាក់ពីសេចក្តីថ្លែងការណ៍ពីមុនរបស់គាត់ ដែលធ្វើឡើងជាមួយនឹងការិយាល័យសហចៅក្រមស៊ើបសង្កេត គាត់បានប្រាប់តុលាការយ៉ាងត្រង់ថា គាត់មិនអាចចាំយ៉ាងលម្អិតនោះទេ បើទោះបីជាគាត់បានអានសេចក្តីថ្លែងការណ៍នោះឡើងវិញក៏ដោយ។ គាត់បានសុំទោសដដែលៗ នៅពេលដែលគាត់មិនអាចចងចាំយ៉ាងច្បាស់លាស់អំពីកាលបរិច្ឆេទ ឬក៏ព្រឹត្តិការណ៍នានា។ គាត់បានប្តេជ្ញាចិត្តថា នឹងឆ្លើយសំណួរទាំងអស់តាមការពិត ហើយបានស្នើសុំថា អង្គជំនុំជម្រះគួរតែធ្វើការវិនិច្ឆ័យដោយខ្លួនឯងផ្ទាល់ ពាក់ព័ន្ធនឹងភាពស៊ីគ្នានៃសក្ខីកម្មរបស់គាត់។ គាត់ហាក់ដូចជាមានបំណងក្នុងការជួយភាគីទាំងអស់ ឲ្យទទួលបាននូវព័ត៌មានដែលត្រឹមត្រូវ ហើយមានពេលមួយ គាត់បានស្នើផ្តល់ជំនួយដល់សហព្រះរាជអាជ្ញា **វ៉ាយដ៍ ដេស្មាឯល** នៅពេលដែលគាត់មានការលំបាកក្នុងការអានឈ្មោះរបស់ខ្មែរ។

## ផ្នែកទី ៣៖ បញ្ហាច្បាប់ និងនីតិវិធី

នាសប្តាហ៍នេះ មានបញ្ហាច្បាប់ និងនីតិវិធីជាច្រើន បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ។ កាលពីថ្ងៃចន្ទ ទំហំនៃការលើកលែងចំពោះសាច់ញាតិរបស់ជនជាប់ចោទក្នុងការធ្វើសម្បថ ត្រូវបានលើកយកមកពិភាក្សា ដោយបានសម្រេចថា ការលើកលែងមួយផ្នែក គឺសមរម្យហើយ ដោយសារតែសាក្សីមាន

កាតព្វកិច្ចក្នុងការឆ្លើយប្រាប់នូវការពិត ពាក់ព័ន្ធនឹងសហជនជាប់ចោទ **នួន ជា**។ អំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់លោកស្រី **សូ សុជាតិ** មេធាវីជាតិការពារក្តីឲ្យលោក **ខៀវ សំផន** គឺលោក **គង់ សំអុន** បានជំទាស់ជាច្រើនដង ទាក់ទិននឹងប្រភេទសំណួររបស់ព្រះរាជអាជ្ញា **វេយ៍ន័រ** ដោយសម្អាងថា សំណួរដែលបានសួរគឺទាមទារឲ្យសាក្សីផ្តល់នូវសក្ខីកម្ម ដែលហួសពីសមត្ថភាពនៃការដឹងរបស់លោកស្រី។ គាត់ក៏បានធ្វើការជំទាស់ផងដែរ អំពីចរិតលក្ខណៈ និងទម្រង់ឯកសារ ដែលព្រះរាជអាជ្ញា **វេយ៍ន័រ** បានបង្ហាញដល់សាក្សី។ ការសួរដេញដោលរវាងព្រះរាជអាជ្ញា **វេយ៍ន័រ** និងមេធាវីការពារក្តី **គង់ សំអុន** គឺកាន់តែកើនឡើងៗ រហូតដល់ចុងបញ្ចប់នៃសប្តាហ៍។ នៅថ្ងៃអង្គារ មេធាវីការពារក្តី **គង់ សំអុន** បានព្យាយាមបំភ្លឺនូវអ្វី ដែលសាក្សីនិយាយក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់លោកស្រី ហើយនៅថ្ងៃបន្ទាប់ ព្រះរាជអាជ្ញា **វេយ៍ន័រ** បានស្នើអង្គជំនុំជម្រះ ឲ្យអនុវត្តបទបញ្ញត្តិនៃការប្រព្រឹត្តមិនត្រឹមត្រូវរបស់មេធាវី ប្រឆាំងនឹងគាត់ ដោយយោងតាមវិធានផ្ទៃក្នុងលេខ ៣៨[៦]។ បញ្ហាដទៃទៀតជាច្រើន ត្រូវបានលើកឡើងក្នុងពេលនៃការផ្តល់សក្ខីកម្មរបស់លោកស្រី **សូ សុជាតិ** នៅពេលដែលលោកស្រីបានរំលឹកដោយអចេតនា ពីឈ្មោះរបស់សាក្សីម្នាក់ ដែលមិនទាន់បានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ហើយបានផ្តល់នូវការអធិប្បាយបន្ថែម ទៅលើចរិតលក្ខណៈរបស់លោក **ខៀវ សំផន** បន្ទាប់ពីបានបញ្ចប់ការផ្តល់សក្ខីកម្មរបស់លោកស្រី។ នៅថ្ងៃព្រហស្បតិ៍ កិច្ចប្រជុំនៃការគ្រប់គ្រងដំណើរការកាត់ក្តីជាសាធារណៈលើកដំបូងរបស់ អ.វ.ត.ក បានចាប់ផ្តើម។ កិច្ចប្រជុំនៃការគ្រប់គ្រងដំណើរការកាត់ក្តី បានលើកឡើងពីបញ្ហាជាច្រើន រួមមាន នីតិវិធីសម្រាប់សវនាការលើឯកសារចុងក្រោយ ការសួរសំណួររបស់ជនជាប់ចោទ សារណាសង្ខេប និងសេចក្តីសន្និដ្ឋានចុងក្រោយ សវនាការនាពេលអនាគត សំណាងផុសផុលផ្លូវចិត្ត និងការបកប្រែដែលនៅសេសសល់។

### ក. ការលើកលែងការស្បថមួយផ្នែកសម្រាប់សាក្សីអត្តចរិតរបស់លោក ខៀវ សំផន

កាលពីថ្ងៃចន្ទ សាក្សី **ទន់ សឿន** និងលោកស្រី **សូ សុជាតិ** បានស្បថតែមួយផ្នែកប៉ុណ្ណោះ (ទាក់ទងនឹងព័ត៌មាន ដែលពួកគេអាចនឹងផ្តល់អំពីលោក **នួន ជា**) មុនពេលនៃការផ្តល់សក្ខីកម្ម។ យោងតាមវិធានផ្ទៃក្នុង២៤.២ សាច់ញាតិរបស់ជនជាប់ចោទ អាចផ្តល់សក្ខីកម្មដោយមិនចាំបាច់ធ្វើសម្បថជាមុន។ ប៉ុន្តែ អង្គជំនុំជម្រះបានសម្រេចថា ការលើកលែងនេះអាចអនុវត្តបានតែមួយផ្នែកប៉ុណ្ណោះ ដោយហេតុថា សំណុំរឿង០០២ មានសហជនជាប់ចោទពីររូប ហើយសាក្សី គឺជាសាច់ញាតិរបស់លោក **ខៀវ សំផន** តែម្នាក់ប៉ុណ្ណោះ។ ការអនុវត្តក្នុងការលើកលែងសម្បថមួយផ្នែក បានបណ្តាលឲ្យមានការភ័ន្តច្រឡំមួយចំនួន ដូចជាថា តើផ្នែកមួយណាឲ្យពិតប្រាកដនៅក្នុងសក្ខីកម្មរបស់សាក្សី ដែលស្ថិតនៅក្នុងការស្បថ ជាពិសេស គឺនៅពេលដែលសាក្សី **សូ សុជាតិ** ផ្តល់សក្ខីកម្មអំពីព្រឹត្តិការណ៍មួយចំនួន ដែលពាក់ព័ន្ធទាំងស្វាមីរបស់គាត់ គឺលោក **ខៀវ សំផន** និងលោក **នួន ជា**។

### ខ. សំណួរហួសពីសមត្ថភាពនៃការយល់ដឹងរបស់សាក្សី

នាថ្ងៃអង្គារ អង្គជំនុំជម្រះបានគាំទ្រនឹងការជំទាស់ ដែលបានលើកឡើងដោយមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** គឺលោក **គង់ សំអុន** ទាក់ទិននឹងសំណួរបែបសន្និដ្ឋាន ដែលបានលើកឡើងព្រះរាជអាជ្ញា **វេយ៍ន័រ** ។ ព្រះរាជអាជ្ញា **វេយ៍ន័រ** បានសួរលោកស្រី **សូ សុជាតិ** ថា តើលោក **ខៀវ សំផន** ធ្លាប់បាននិយាយប្រាប់គាត់ពីលោក **ហ៊ូ នឹម** ដែលជាបញ្ញវន្តមួយរូប ត្រូវបានគេចាប់ខ្លួនក្នុងឆ្នាំ១៩៧៧ បានសរសេរ

សំបុត្រឲ្យគាត់មួយច្បាប់ស្តីពីការចាប់ខ្លួនរបស់គាត់។ បន្ទាប់ពីសាក្សីបានឆ្លើយតបថា លោកស្រីមិនដែលបានដឹងពីសំបុត្រនោះទេ ព្រះរាជអាជ្ញា **វេយ៍ន័រ** បានសួរលោកស្រីថា ហេតុអ្វីបានជាលោក **ហ៊ូ នឹម** សរសេរសំបុត្របែបនេះ។ មេធាវី **គង់ សំអុន** បានជំទាស់នឹងសំណួរនេះ ដោយបានប្រកាសថា វាអាចនឹងនាំទៅរកការផ្តល់សក្ខីកម្មបែបសន្និដ្ឋាន។ បន្ទាប់ពីមានកិច្ចពិភាក្សាយ៉ាងយកចិត្តទុកដាក់របស់អង្គជំនុំជម្រះមក លោកប្រធានអង្គជំនុំជម្រះបានគាំទ្រការជំទាស់ ហើយបានបង្គាប់មិនឲ្យសាក្សីឆ្លើយតបនឹងសំណួរនេះ។

មេធាវី **គង់ សំអុន** បានជំទាស់សាជាថ្មីម្តងទៀត ពាក់ព័ន្ធនឹងសំណួរដែលសួរដោយសហព្រះរាជអាជ្ញា **វេយ៍ន័រ** ទៅកាន់លោកស្រី **សូ សុជាតិ** អំពីសៀវភៅគ្រួសាររបស់លោកស្រី ដែលបានចុះកាលបរិច្ឆេទពីថ្ងៃដែលកូនប្រុសរបស់លោកស្រីបានប្រសូត្រ។ មេធាវីការពារក្តី **គង់ សំអុន** បានអះអាងថា សហព្រះរាជអាជ្ញា **វេយ៍ន័រ** បានកំពុងសួរសំណួរដែលទាក់ទងនឹងនីតិវិធីលម្អិត ស្តីអំពីដំណើរការនៃការចុះបញ្ជីឈ្មោះដែលសាក្សីមិនមានលទ្ធភាពក្នុងការឆ្លើយបាន។ សហព្រះរាជអាជ្ញា **វេយ៍ន័រ** បានបកស្រាយថា គាត់មានបំណងឲ្យសាក្សីពន្យល់ថា ហេតុអ្វីបានជាថ្ងៃកំណើតកូនប្រុសរបស់លោកស្រី ដែលបានចុះក្នុងបញ្ជីខុសពីកាលបរិច្ឆេទ ដែលលោកស្រីផ្តល់ឲ្យនៅក្នុងសេចក្តីថ្លែងការណ៍ ពោល វាគឺជាបញ្ហាមួយដែលបានលើកឡើងដោយចៅក្រម **ឡាវែន៍** ប៉ុន្តែនៅតែមិនទាន់មានដំណោះស្រាយនៅឡើយ។ បន្ទាប់ពីមានកិច្ចប្រជុំមួយរវាងអង្គជំនុំជម្រះមក លោកប្រធាន បានច្រានចោលនូវការជំទាស់ ដោយបានបញ្ជាក់ថា មិនមានសម្អាងហេតុដ៏សមរម្យ។

## គ. ការប្រើប្រាស់ និងការកំណត់ឯកសារសម្រាប់ប្រើក្នុងពេលសាកសួរ

ការជំទាស់ជាច្រើន ត្រូវបានលើកឡើងដោយមេធាវីការពារក្តី ពាក់ព័ន្ធនឹងការប្រើប្រាស់ឯកសាររបស់សហព្រះរាជអាជ្ញា **វេយ៍ន័រ** ក្នុងអំឡុងពេលនៃការសាកសួរលោកស្រី **សូ សុជាតិ**។ នាថ្ងៃអង្គារ ក្នុងពេលនៃការសាកសួររបស់ព្រះរាជអាជ្ញាទៅកាន់លោកស្រី **សូ សុជាតិ** លោកមេធាវី **គង់ សំអុន** បានជំទាស់នឹងព្រះរាជអាជ្ញា **វេយ៍ន័រ** ទាក់ទិននឹងការយោងឯកសារដោយមិនបានស្រង់នូវលេខសម្គាល់នៃឯកសារនោះ (ERN)។ ព្រះរាជអាជ្ញា **វេយ៍ន័រ** បានឆ្លើយតបថា គាត់មិនបានមានលេខសម្គាល់ឯកសារនៅក្នុងដៃនោះទេ ប៉ុន្តែបានស្នើសុំការអនុញ្ញាតប្រើប្រាស់ប្រតិចារឹកជំនួសវិញ ហើយបានបន្ថែមទៀតថា ការអនុវត្តបែបនេះត្រូវបានអនុម័តកាលពីសប្តាហ៍មុន ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ **ស៊ីដនី ស្តេនប៊ឹក**។[7] លោកប្រធាន **និល ណុន** បានអនុញ្ញាតឲ្យព្រះរាជអាជ្ញា **វេយ៍ន័រ** បន្តការសាកសួរដេញដោលដូចនឹងអ្វីដែលគាត់បានស្នើសុំ ដោយបានបញ្ជាក់ថា ប្រតិចារឹកអាចកំណត់សម្គាល់ឯកសារបានច្បាស់លាស់ជាងលេខសម្រាប់សម្គាល់នូវឯកសារទៅទៀត។ នាថ្ងៃពុធ មេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** គឺលោក **វើកគែន** បានជំទាស់នឹងការព្យាយាមរបស់ព្រះរាជអាជ្ញា **វេយ៍ន័រ** ក្នុងការប្រើប្រាស់សារទូរលេខ ដែលក្រុមមេធាវីការពារក្តីមិនមាន។ បន្ទាប់ពីការសុំអភ័យទោសពីសំណាក់ព្រះរាជអាជ្ញា **វេយ៍ន័រ** ដំបូងឡើយ លោកប្រធានបានអនុញ្ញាតឲ្យព្រះរាជអាជ្ញាបន្តកិច្ចដំណើរការនីតិវិធី ប៉ុន្តែក្រោយពេលដែលលោកមេធាវី **វើកគែន** បានបង្ហាញថា សារទូរលេខនោះគឺគ្រាន់តែជាឯកសាររបស់គេហទំព័ររបស់ វីគីឡីក (Wikileaks) លោកប្រធានបានច្រានចោលនូវសំណើរបស់ព្រះរាជអាជ្ញា ក្នុងការយោងទៅលើសារទូរលេខនោះ។

### ឃ. ការលាតត្រដាងឈ្មោះរបស់សាក្សីនាពេលអនាគត

ក្នុងអំឡុងពេលនៃការសាកសួរដោយចៅក្រម **ឡាវើន៍** កាលពីថ្ងៃអង្គារ សាក្សី **សូ សុជាតិ** បាននិយាយដោយអចេតនា អំពីឈ្មោះរបស់សាក្សីនាពេលអនាគតមួយរូប បើទោះបីជាមានការព្រមានមិនឲ្យឆ្លើយ ប្រសិនបើលោកស្រីបានស្គាល់មនុស្ស ដែលមានឈ្មោះនៅក្នុងឯកសារដែលបានផ្ដល់ឲ្យលោកស្រីក៏ដោយ លើកលែងតែលោកស្រីមិននិយាយពីឈ្មោះរបស់ពួកគេ។ វិធានផ្ទៃក្នុងលេខ ២៩ បានចែងថា ការបិទបាំងអត្តសញ្ញាណរបស់សាក្សី គឺគ្រាន់តែតម្រូវឲ្យមានវិធានការការពារនៅពេលដែលចាំបាច់ប៉ុណ្ណោះ ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា បានអនុម័តការអនុវត្តនៃការបិទបាំងឈ្មោះរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីពីសាធារណៈ រហូតដល់ពួកគេមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។[8]

### ង. សេចក្ដីថ្លែងការណ៍បន្ថែមរបស់សាក្សី បន្ទាប់ពីបានបញ្ចប់ការផ្ដល់សក្ខីកម្ម

កាលពីថ្ងៃពុធ បន្ទាប់ពីបានបញ្ចប់ការផ្ដល់សក្ខីកម្មរបស់គាត់ លោកស្រី **សូ សុជាតិ** បានបន្តផ្ដល់សេចក្ដីថ្លែងការណ៍បន្ថែម អំពីចរិតលក្ខណៈរបស់លោក **ខៀវ សំផន** ។ ព្រះរាជអាជ្ញា **វេយ៍ន័រ** បានប្រកាសថា លោកស្រី **សូ សុជាតិ** មិនមែនជាដើមបណ្ដឹងរដ្ឋប្បវេណីទេ ដូច្នេះ គឺមិនត្រូវបានអនុញ្ញាតឲ្យបង្ហាញភស្តុតាងពីចរិតលក្ខណៈ ដែលមិនមែនជាប្រធានបទនៃការសាកសួរដេញដោលឡើយ។[9] ក្រោយមក មេធាវីប្រឹក្សាបានការពារលោកស្រី **សូ សុជាតិ** ដោយបានបង្ហាញថា ភាគីមួយចំនួនបានចោទប្រកាន់លោកស្រីថាបាននិយាយកុហក ហើយថា លោកស្រីមានបំណងធ្វើសេចក្ដីថ្លែងការណ៍មួយ ដើម្បីទាញយកបញ្ហានេះ។ លោកប្រធាន **និល ណុន** បានក្រើនរំលឹកមេធាវីប្រឹក្សា ដោយបានបញ្ជាក់ថា តួនាទីរបស់មេធាវីប្រឹក្សានៅក្នុងកិច្ចដំណើរការនីតិវិធី គឺបានកម្រិតត្រឹមផ្ដល់ដំបូន្មានដល់សាក្សី ទាក់ទិននឹងការដាក់បន្ទុកផ្នែកព្រហ្មទណ្ឌ។[10]

### ច. ពាក្យស្នើសុំរបស់សហព្រះរាជអាជ្ញា ចំពោះការប្រព្រឹត្តមិនត្រឹមត្រូវរបស់មេធាវី អនុលោមតាមវិធានផ្ទៃក្នុង មាត្រា៣៨

នាថ្ងៃពុធ សហព្រះរាជអាជ្ញាអន្តរជាតិ **វេយ៍ន័រ** បានដាក់ពាក្យស្នើសុំមួយអនុលោមតាមវិធានផ្ទៃក្នុងមាត្រា៣៨ [11] ដើម្បីអនុវត្តប្រឆាំងនឹងមេធាវីជាតិការពារក្ដីឲ្យលោក **ខៀវ សំផន** គឺលោក **គង់ សំអុន**។ ព្រះរាជអាជ្ញា **វេយ៍ន័រ** បានលើកទឡ្ហីករណ៍ថា បំណងរបស់លោកមេធាវីការពារក្ដី **គង់ សំអុន** ក្នុងការបញ្ជាក់ពីអ្វីដែលលោកស្រី **សូ សុជាតិ** "ចង់បញ្ជាក់" កាលពីថ្ងៃមុន គឺស្មើនឹងការជ្រៀតជ្រែកដោយចេតនា ក្នុងការស្វែងរកយុត្តិធម៌។ គាត់បានស្នើសុំអង្គជំនុំជម្រះ ឲ្យធ្វើការស្ដីបន្ទោសលោកមេធាវីការពារក្ដី **គង់ សំអុន** ជាផ្លូវការ និងរាយការណ៍ពីអាកប្បកិរិយារបស់គាត់ទៅកាន់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងផ្ដល់ឲ្យគាត់នូវការព្រមានជាលក្ខណៈផ្លូវការមួយថា ឥរិយាបថដដែលៗនេះ អាចនាំឲ្យឈានដល់មានការដកតំណែងគាត់ចេញពីតុលាការ។ លោកមេធាវី **គង់ សំអុន** បានបដិសេធថា គាត់បានកំពុងព្យាយាមផ្ដល់ព័ត៌មានទៅឲ្យសាក្សីដោយបានបញ្ជាក់ថា គាត់ "ក្នុងនាមជាមេធាវីម្នាក់ ដែលចូលរួមក្នុងនីតិវិធីនេះ ដើម្បីពិនិត្យ" កែប្រែភាពមិនស្របគ្នានៅក្នុងប្រតិចារឹក។ ទាំងលោកមេធាវី **វែកគែន** និងមេធាវីអន្តរជាតិការពារក្ដីឲ្យលោក **នួន ជា** គឺលោក **វិចទ័រ កូប៉េ** បានរិះគន់ការស្នើសុំរបស់សហព្រះរាជអាជ្ញា។ លោក **វែកគែន** បានអះអាងថា សំណើសុំនេះ គឺ

គ្រាន់តែជាបំណងមួយដើម្បី "បំភ័យ" ប៉ុណ្ណោះ។ ក្រោយពីការគាំទ្រពីសំណាក់ក្រុមមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** មក លោកមេធាវី **កូប៉េ** បានបន្ថែមថា សំណើសុំនេះគឺ "មិនអាចទទួលយកបានទេ"។

## ឆ. កិច្ចពិភាក្សាស្តីពីការគ្រប់គ្រងសវនាការ

*សវនាការស្តីពីឯកសារចុងក្រោយ*

កាលពីថ្ងៃព្រហស្បតិ៍ កិច្ចពិភាក្សាស្តីពីការគ្រប់គ្រងសវនាការ បានចាប់ផ្តើមជាមួយការដាក់ឯកសារផ្ទាល់មាត់ពីសំណាក់ភាគីទាំងអស់ ពាក់ព័ន្ធនឹងផែនការសម្រាប់សវនាការលើឯកសារចុងក្រោយ ដែលដំបូងឡើយ គឺគ្រោងនឹងធ្វើឡើងនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣។ លោកប្រធាន **និល ណុន** បានបញ្ជាក់ថា គោលបំណងនៃសវនាការនេះ គឺផ្តល់ឱកាសជាចុងក្រោយមួយសម្រាប់ភាគី បង្ហាញឯកសារសំខាន់ៗទាក់ទងនឹងឧក្រិដ្ឋកម្មរួម ដែលគោរពទៅតាមតួនាទីរបស់ជនជាប់ចោទ។ សហព្រះរាជអាជ្ញាអន្តរជាតិ **វីល្លៀម ស្មីត** និងសហមេធាវីអន្តរជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណីលោកស្រី **អេលីហ្សាបេត ស៊ីម៉ុនណូហ្វត** បានព្រមព្រៀងថា សហព្រះរាជអាជ្ញា ត្រូវការរយៈពេលបីថ្ងៃ ហើយមេធាវីអន្តរជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ត្រូវការរយៈពេលមួយថ្ងៃកន្លះ ដើម្បីបង្ហាញឯកសារ។ មេធាវីការពារក្តីឲ្យលោក **នួន ជា** មិនមានបំណងបង្ហាញឯកសារណាមួយឡើយ ប៉ុន្តែត្រូវការរយៈច្រើនបំផុតមួយថ្ងៃដើម្បីឆ្លើយតបនឹងឯកសារ ដែលបានបង្ហាញដោយភាគីនានា។

មេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** បាននិយាយដដែលៗ ពីការចោទប្រកាន់របស់ពួកគេថា សវនាការស្តីពីឯកសាររហូតមកដល់ពេលនេះ បានរារាំងកូនក្តីរបស់ពួកគេក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងបានស្នើសុំថា សវនាការទទួលយកឯកសារគួរតែត្រូវបានធ្វើឡើង។[12] មេធាវី **វែកគែន** បានលើកទឡ្ហីករណ៍ថា ក្រុមមេធាវីការពារក្តីគួរតែមានឱកាសក្នុងការតតាំងនឹងរាល់ឯកសារទាំងអស់ដែលបានបង្ហាញ នៅក្នុងការកំណត់សវនាការដេញដោលមួយ ដោយបានបញ្ជាក់ថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះ បានរារាំងមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** ពីការធ្វើអធិប្បាយលើសារប្រយោជន៍ និងតម្លៃសាកល្បងនៃឯកសារ ក្នុងអំឡុងពេលនៃសវនាការស្តីពីឯកសារ កាលពីបីដងមុន។[13]

លោកប្រធានបានពន្យល់ថា ឯកសារដែលអាចប្រើប្រាស់បាន ត្រូវបានគេកំណត់ក្នុងអំឡុងពេលនៃសវនាការដំបូងរួចមកហើយ ហើយថែមទាំងបានបញ្ជាក់ថា គោលបំណងនៃសវនាការ គឺដើម្បីបង្ហាញឯកសារសំខាន់ៗ ដែលបានទទួលយកជាភស្តុតាង នៅក្នុងតុលាការ និងជាសាធារណៈរួចមកហើយ។ លោកប្រធានសង្កត់ធ្ងន់ថា វាមិនត្រឹមត្រូវទេសម្រាប់ក្រុមមេធាវីការពារក្តី ក្នុងការលើកទឡ្ហីករណ៍សាជាថ្មីចំពោះការទទួលយកភស្តុតាង។ ទោះបីជាយ៉ាងណា ពួកគេត្រូវបានគេបើកឱកាសឲ្យដាក់ទឡ្ហីករណ៍នានា ទាក់ទិននឹងតម្លៃសាកល្បងនៃឯកសារដែលត្រូវបានបង្ហាញ។ លោកមេធាវី **វែកគែន** បានលើកឡើងថា វាផ្ទុយនឹងការអនុវត្តកាលពីមុន។ ទោះបីជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញា **ស្មីត** បានច្រានចោលនូវការចោទប្រកាន់របស់លោកមេធាវី **វែកគែន** ហើយបានរំលឹកមេធាវីការពារក្តីរបស់លោក **ខៀវ សំផន** ថា ពួកគេត្រូវបានគេផ្តល់ឱកាសមួយឲ្យតតាំងនឹងការទទួលយកភស្តុតាង និងតម្លៃសាកល្បងដែលពាក់ព័ន្ធនឹងឯកសារទាំងអស់ ប៉ុន្តែពួកគេបានធ្លោះធ្លោយក្នុងការចូលរួម។[14]

## *សំណួររបស់សហជនជាប់ចោទ*

អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីទាំងអស់ថា សហជនជាប់ចោទបានជ្រើសរើសឆ្លើយតបនឹងសំណួរនានា ហើយជនជាប់ចោទមួយរូបៗ នឹងត្រូវបានគេសួរសំណួររយៈពេលប្រាំមួយថ្ងៃ។ សហព្រះរាជអាជ្ញា **ស្មឺត** បានជំទាស់ទៅនឹងសំណើពីរ ដែលបានធ្វើឡើងដោយក្រុមមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** ពាក់ព័ន្ធនឹងការសួរសំណួររបស់សហជនជាប់ចោទ។ ទីមួយ សហព្រះរាជអាជ្ញា **ស្មឺត** បានជំទាស់ថា ការស្នើសុំរបស់ក្រុមមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** ក្នុងការទទួលបានបញ្ជីមួយស្តីអំពីឯកសារ ឬប្រធានបទនានា ដែលនឹងត្រូវយកមកប្រើប្រាស់ដើម្បីតទល់នឹងជនជាប់ចោទ មុនពេលនៃការសាកសួរដេញដោល គឺមិនស្របទៅតាមវិធានផ្ទៃក្នុង មាត្រា៩០ ទេ។[15] គាត់បានបន្ថែមថា ភាគីទាំងអស់គឺមានជំហរដូចគ្នា ក្នុងការបង្ហាញភស្តុតាងរបស់ពួកគេ ដូចដែលបានតម្រូវតាមវិធានផ្ទៃក្នុង មាត្រា៣៥។ លើសពីនេះទៅទៀត វាមិនយុត្តិធម៌ទេ ប្រសិនបើលោក **ខៀវ សំផន** ត្រូវបានគេផ្តល់ឯកសារ ឬប្រធានបទជាមុន ពីព្រោះក្រុមមេធាវីការពារក្តី មិនដែលបានផ្តល់បញ្ជីបែបនេះ ទៅឲ្យការិយាល័យសហព្រះរាជអាជ្ញាទេ នៅក្នុងអំឡុងពេលនៃការសាកសួរដេញដោលសាក្សី។ សហព្រះរាជអាជ្ញា **ស្មឺត** បានផ្តល់យោបល់ដល់អង្គជំនុំជម្រះឲ្យណែនាំក្រុមមេធាវីការពារក្តី ឲ្យយោងទៅលើលេខនៃកថាខណ្ឌដែលពាក់ព័ន្ធនៅក្នុងដីកាដំណោះស្រាយ ដើម្បីកំណត់ពីប្រធានបទសម្រាប់ការសាកសួរសំណួរ។

ទីពីរ ព្រះរាជអាជ្ញា **ស្មឺត** បានជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** ដើម្បីសម្រាករយៈពេលបីសប្តាហ៍ បន្ទាប់ពីបញ្ចប់សវនាការបង្ហាញភស្តុតាង មុនពេលមានការសាកសួរសហជនជាប់ចោទ ដោយបានបញ្ជាក់ថា ពួកគេមានពេលច្រើនជាងប្រាំឆ្នាំ ក្នុងការរៀបចំនេះ។ មេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** បានលើកទឡ្ហីករណ៍ថា ពួកគេបានទាមទារពេលវេលាបន្ថែមក្នុងការរៀបចំ ដោយសារតែមូលហេតុសុខភាពរបស់កូនក្តីពួកគេ ហើយបានភ្ជាប់មកជាមួយនឹងហេតុផលថា ពួកគេមិនអាចជួបកូនក្តីរបស់ពួកគេ នៅមន្ទីរឃុំឃាំងនាថ្ងៃចុងសប្តាហ៍បាន។

## *សារណាសង្ខេប និងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល*

ភាគីទាំងអស់ បានស្នើសុំអង្គជំនុំជម្រះឲ្យបន្ថែមទំព័រ ដែលបានកម្រិតសម្រាប់សារណាសង្ខេប។ ជាកិច្ចបន្ថែម ទាំងការិយាល័យសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** បានស្នើសុំការពន្យារពេលដើម្បីដាក់សារណាសង្ខេប។ លោកមេធាវី **វ៉េកតែន** ក៏បានស្នើសុំពេលវេលាបន្ថែម(រយៈពេលពីរសប្តាហ៍) ផងដែរ ដើម្បីតាមដានបញ្ហាបកប្រែនៅក្នុងប្រតិចារឹកនានា និងបានថ្លែងថា ពេលវេលាដែលបានបែងចែកឲ្យមេធាវីការពារក្តី ដើម្បីរៀបចំសារណាសង្ខេបរបស់ពួកគេ គួរតែគណនាទៅតាមពេលវេលា ដែលពួកគេបានទទួលសេចក្តីសង្ខេបបញ្ចប់របស់ការិយាល័យសហព្រះរាជអាជ្ញាជាភាសាខ្មែរ ឬភាសាបារាំង តែមិនមែនជាភាសាអង់គ្លេសទេ។ អង្គជំនុំជម្រះបានច្រានចោលសំណើ ហើយបានបញ្ជាក់ថា ភាគីទាំងអស់មានពេលវេលាត្រឹមតែប្រាំមួយសប្តាហ៍ប៉ុណ្ណោះ ដើម្បីដាក់សារណាសង្ខេបរបស់ពួកគេ ជាមួយនឹងចំនួនទំព័រដូចដែលបានកម្រិតក្នុងសេចក្តីសម្រេចកាលពីមុន ហើយសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល នឹងត្រូវធ្វើឡើងក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីការដាក់សារណាសង្ខេបចុងក្រោយ។[16]

*សវនាការនាពេលអនាគត និងអាជ្ញាអស់ជំនុំ*

ក្នុងការឆ្លើយតបនឹងសំណើទៅកាន់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបំភ្លឺអំពីសវនាការនាពេលអនាគត លោកប្រធាន បានណែនាំថា អង្គជំនុំជម្រះមិនអាចកំណត់កាលបរិច្ឆេទអំពីសវនាការនាពេលអនាគត នៅពេលនេះទេ។ គាត់បានពន្យល់ថា សវនាការនាពេលអនាគត អាចប្រព្រឹត្តទៅបានអាស្រ័យលើសុខភាពរបស់ជនជាប់ចោទ ដែលនៅពុំអាចព្យាករណ៍ទុកបានឡើយ ហើយហួសពីសមត្ថភាពនៃការគ្រប់គ្រងរបស់អង្គជំនុំជម្រះ។ នៅពេលដែលលោកស្រី **ស៊ីម៉ុនណូហ្សត** បានធ្វើការស្វែងរកនូវជំហររបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងអាជ្ញាអស់ជំនុំក្នុងសំណុំរឿង ០០២ និងសវនាការបន្តបន្ទាប់ លោកស្រីចៅក្រម **ខាត់វ៉ាយច៍** បាននិយាយថា វានៅតែមិនទាន់ពេញលក្ខណៈសម្រាប់ការពិភាក្សាអំពីបញ្ហានេះ រហូតទាល់តែអង្គជំនុំជម្រះតុលាការកំពូល ចេញសេចក្តីសម្រេចអំពីដីកាបំបែកសំណុំរឿង។ លោកស្រី បានបន្ថែមថា អង្គជំនុំជម្រះមានបំណងរៀបចំកិច្ចពិភាក្សាស្តីពីការគ្រប់គ្រងសវនាការមួយ ដើម្បីអនុញ្ញាតឲ្យភាគីពិភាក្សាដេញដោលអំពីអាជ្ញាអស់ជំនុំ បន្ទាប់ពីបញ្ចប់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។

*ការជួសជុលសំណងខូចខាត*

អង្គជំនុំជម្រះ បានគូសបញ្ជាក់ថា គេមិនបានរំពឹងទេថា សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីនឹងផ្តល់សារណាចុងក្រោយ ទាក់ទងនឹងការជួសជុលសំណងខូចខាត “បានយ៉ាងឆាប់រហ័សនោះទេ” ហើយបញ្ហានេះនឹងត្រូវដោះស្រាយ នាពេលក្រោយ ក្នុងឆ្នាំនេះ។

*ការបកប្រែដែលនៅសេសសល់*

លោកប្រធាន **និល ណុន** បានរំលឹកអង្គជំនុំជម្រះថា នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៣ ការិយាល័យសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី បានប្រកាសថា ពួកគេមិនអាចបញ្ចប់ការបកប្រែឯកសារដែលនៅសេសសល់ ឲ្យទាន់ពេលវេលាដែលបានកំណត់នោះទេ និងថែមទាំងបានស្នើសុំថា តើឯកសារបកប្រែដែលនៅសេលសល់ អាចនឹងបញ្ចប់នៅមុនពេលផ្តល់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលបានដែរ ឬយ៉ាងណា គឺប្រហែលជានៅខែតុលា ឆ្នាំ២០១៣។ ទាំងសហព្រះរាជអាជ្ញា **ខេល លីសាក់** និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **ស៊ីម៉ូណូហ្សត** បានជម្រាបជូនតុលាការទាំងមូលថា ការបកប្រែបានកំពុងដំណើរការ ហើយអាចនឹងបញ្ចប់ក្នុងរយៈពេលមួយខែ ឬពីរខែទៀត។

## ផ្នែកទី ៤៖ ការគ្រប់គ្រងសវនាការ

នាសប្តាហ៍នេះ បើទោះបីជាមានការជំទាស់ជាច្រើន ត្រូវបានលើកឡើងដោយភាគីក៏ដោយ ប៉ុន្តែអង្គជំនុំជម្រះនៅតែអាចគ្រប់គ្រងសវនាការ ដោយបានបញ្ចប់ការស្តាប់សក្ខីកម្មទាំងអស់ពីសាក្សីចំនួនបីរូប និងបានរៀបចំកិច្ចពិភាក្សាអំពីការគ្រប់គ្រងសវនាការចុងក្រោយផងដែរ។ អង្គជំនុំជម្រះ បានខិតខំប្រឹងប្រែងក្នុងការដំណើរការកិច្ចដំណើរការនីតិវិធី យ៉ាងមានប្រសិទ្ធភាព ទោះបីជា មិនបានបង្ហាញនូវភាពបត់បែនមួយចំនួន កាលពីថ្ងៃពុធក៏ដោយ ជាពិសេស គឺនៅពេលដែលពួកគេអនុញ្ញាតឲ្យការិយាល័យសហព្រះរាជអាជ្ញាសាកសួរសាក្សី **សូ សុជាតិ** ហួសពីពេលវេលាដែលបានកំណត់ទុក។

## ក.	វត្តមាន

លោក នួន ជា បានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីចម្ងាយ គឺពីបន្ទប់ឃុំឃាំងនៅក្រោមបន្ទប់សវនាការ ដោយសារតែបញ្ហាសុខភាព។ លោក **ខៀវ សំផន** មានវត្តមាននៅក្នុងបន្ទប់សវនាការ ស្ទើរតែពេញមួយសប្ដាហ៍ ប៉ុន្តែបានអវត្តមានក្នុងអំឡុងពេលនៃកិច្ចពិភាក្សាអំពីការគ្រប់គ្រងសវនាការ និងសវនាការចុងក្រោយ នារសៀលថ្ងៃព្រហស្បតិ៍។

**វត្តមានចៅក្រម៖** ចៅក្រមបម្រុង **ក្លូឌា ហ្វេនស៍** បានអវត្តមានពេញមួយសប្ដាហ៍។

**វត្តមានដើមបណ្ដឹងរដ្ឋប្បវេណី៖** ក្រុមអ្នកឃ្លាំមើលសាលាក្ដីខ្មែរក្រហម បានសង្កេតឃើញមានដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១០ នាក់ បានតាមដានកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ពីក្នុងបន្ទប់សវនាការ និងដើមបណ្ដឹងរដ្ឋប្បវេណីប្រហែលជា ២០ នាក់ផ្សេងទៀត បានតាមដានកិច្ចដំណើរការនីតិវិធីពីសាលសវនាការសាធារណៈ។

**វត្តមានភាគី៖** ភាគីទាំងអស់ត្រូវបានតំណាងជាប្រក្រតី នាសប្ដាហ៍នេះ លើកលែងតែសហមេធាវីជាតិនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី គឺលោក **ពេជ អង្គ** ដែលបានអវត្តមាននៅព្រឹកថ្ងៃអង្គារ ដោយសារមូលហេតុផ្ទាល់ខ្លួន។

**វត្តមានសាធារណជន ៖**

| កាលបរិច្ឆេទ | ពេលព្រឹក | ពេលរសៀល |
|---|---|---|
| ថ្ងៃចន្ទ ១០/០៦/១៣ | • ប្រជាជនចំនួន ៥៥០នាក់ រួមមាន សិស្សមកពីទីក្រុងភ្នំពេញ បូករួមទាំងអ្នកភូមិ និងជនជាតិចាម មកពីខេត្តព្រៃវែង<br>• អ្នកសង្កេតការណ៍បរទេសចំនួន ១៥ នាក់ | • សិស្សចំនួន ២០០នាក់ មកពីទីក្រុងភ្នំពេញ<br>• អ្នកភូមិចំនួន ២៥០ នាក់ មកពីខេត្តតាកែវ |
| ថ្ងៃអង្គារ ១១/០៦/១៣ | • សិស្សចំនួន ៥៥០នាក់ មកពីវិទ្យាល័យ ក្នុងខេត្តកំពង់ធំ<br>• អ្នកសង្កេតការណ៍បរទេសចំនួន ៥នាក់ | • យុវជនចំនួន ២៥០នាក់ មកពីសមាគមយុវជនកម្ពុជា<br>• អ្នកសង្កេតការណ៍បរទេសចំនួន ៤នាក់ |
| ថ្ងៃពុធ ១២/០៦/១៣ | • និស្សិតចំនួន ៥០០ នាក់ មកពីទីក្រុងភ្នំពេញ និងសាកលវិទ្យាល័យឯកទេសនៃកម្ពុជា ប្រចាំខេត្តកំពង់ចាម<br>• ព្រះសង្ឃចំនួន ៥០ អង្គ<br>• អ្នកសង្កេតការណ៍បរទេស ១ នាក់ | • និស្សិតចំនួន ៤០០ នាក់ មកពីទីក្រុងភ្នំពេញ និងខេត្តកំពង់ចាម<br>• ព្រះសង្ឃចំនួន ៥ អង្គ<br>• អ្នកសង្កេតការណ៍បរទេសចំនួន ២ នាក់ |
| ថ្ងៃព្រហស្បតិ៍ ១៣/០៦/១៣ | • និស្សិតចំនួន ៥០០ នាក់ មកពីទីក្រុងភ្នំពេញ និងខេត្តកំពង់ចាម<br>• អ្នកសង្កេតការណ៍បរទេសចំនួន ៨ នាក់ | • និស្សិតចំនួន ៥០០ នាក់ មកពីខេត្តកំពង់ចាម និងទីក្រុងភ្នំពេញ |

## ខ. ការគ្រប់គ្រងពេលវេលា

នាសប្តាហ៍នេះ អង្គជំនុំជម្រះបានដំណើរការសវនាការចាប់ពីថ្ងៃចន្ទ រហូតដល់ថ្ងៃព្រហស្បតិ៍ ដោយបានបញ្ចប់ការផ្តល់សក្ខីកម្មរបស់សាក្សីចំនួនបីរូប និងបានបញ្ចប់កិច្ចពិភាក្សាអំពីការគ្រប់គ្រងសវនាការ យោងទៅតាមកាលវិភាគដែលបានកំណត់ទុក។ ការផ្តល់សក្ខីកម្មរបស់សាក្សី **សូ សុជាតិ** បានប្រព្រឹត្តហួសពីពេលវេលាកំណត់ ប៉ុន្តែបញ្ហានេះ មិនបានបង្កជាបញ្ហានោះទេ ដោយសារតែការផ្តល់សក្ខីកម្មរបស់សាក្សីពីររូបផ្សេងទៀត បានបញ្ចប់មុនពេលវេលាកំណត់។

## គ. ឥរិយាបថក្នុងបន្ទប់សវនាការ

បញ្ហាឥរិយាបថក្នុងបន្ទប់សវនាការមួយចំនួន ត្រូវបានលើកឡើងពេញមួយសប្តាហ៍ ពាក់ព័ន្ធនឹងការតទល់រវាងសហព្រះរាជអាជ្ញា **រេយ៍ន័រ** និងមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន**។ កាលពីថ្ងៃអង្គារ ក្នុងអំឡុងពេលនៃការសាកសួរដេញដោលរបស់ការិយាល័យសហព្រះរាជអាជ្ញា ទៅកាន់សាក្សី **សូ សុជាតិ** លោកមេធាវី **គង់ សំអុន** បានផ្តល់នូវការបកស្រាយដោយខ្លួនគាត់ផ្ទាល់ នូវអ្វីដែលសាក្សីបាននិយាយ។ សហព្រះរាជអាជ្ញា **រេយ៍ន័រ** បានអះអាងថា ទង្វើរបស់លោកមេធាវី **គង់ សំអុន** បានចាត់ទុកជា "មូលដ្ឋានមួយនៃការបំពានក្រមសីលធម៌វិជ្ជាជីវៈ" ហើយនៅថ្ងៃបន្ទាប់ គាត់បានដាក់ពាក្យស្នើសុំទៅកាន់អង្គជំនុំជម្រះដើម្បីអនុវត្តបទបញ្ញត្តិនៃការប្រព្រឹត្តមិនសមស្រប ប្រឆាំងនឹងមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** (សូមមើលផ្នែកទី ៣.ច)។ មានពេលមួយផ្សេងទៀត នៅក្នុងអំឡុងពេលដែលការិយាល័យសហព្រះរាជអាជ្ញា ធ្វើការសាកសួរដេញដោលសាក្សី មេធាវី **វែកគែន** បានជំទាស់ទៅនឹងការប្រើប្រាស់ការដកស្រង់ឃ្លាដ៏ទូលំទូលាយមួយ ដែលភ្លាមនោះ នាំឲ្យសហព្រះរាជអាជ្ញា **រេយ៍ន័រ** ចោទប្រកាន់មេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** ថា បានកាត់ការសាកសួរដេញដោលរបស់គាត់ "ជាពិសេសការដែលលើកឡើងថា អ្វីដែលខ្ញុំធ្វើឡើងនេះជាការសន្និដ្ឋាន"។ វិធីសាស្ត្រនៃការសាកសួរដេញដោលរបស់សហព្រះរាជអាជ្ញា **រេយ៍ន័រ** ក៏ត្រូវបានរិះគន់ផងដែរ ពីសំណាក់មេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** ដែលបានអះអាងថា ការហៅសាក្សីថាជា "មនុស្សកុហក" គឺជាការមិនគោរព និងមិនសមរម្យ។

## ឃ. បញ្ហាបកប្រែ និងបច្ចេកទេស

នាសប្តាហ៍នេះ មានបណ្តឹងតវ៉ាជាច្រើន ត្រូវបានលើកឡើងទាក់ទងនឹងគុណភាព និងកង្វះខាតនៃការបកប្រែ។ មានពេលជាច្រើន លោក **វែកគែន** បានជម្រាបជូនតុលាការថា មិនមានការបកប្រែពីភាសាអង់គ្លេស ទៅជាបារាំង ឬថា សេចក្តីថ្លែងការណ៍ត្រូវបានគេសង្ខេបឲ្យខ្លី។ អង្គភាពបកប្រែភាសាបានឆ្លើយតបថាលោក **វែកគែន** មិនបានផ្តល់ការឈប់សម្រាកឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យគេបកប្រែពាក្យសំដីរបស់គាត់ទេ។ អ្នកឃ្លាំមើលសាលាក្តីខ្មែរក្រហម បានសង្កេតឃើញថា ភាគីពិតជាបាននិយាយយ៉ាងលឿន ពេញមួយសប្តាហ៍នេះ លើកលែងតែ សហព្រះរាជអាជ្ញា **រេយ៍ន័រ** ដែលត្រូវបានគេសង្កេតឃើញថា បាននិយាយយ៉ាងច្បាស់ៗ និងយឺតៗ។

## ង.	តារាងពេលវេលា

| កាលបរិច្ឆេទ | សវនការ ពេលព្រឹក១ | សវនាការ ពេលព្រឹក២ | សវនាការ ពេលរសៀល១ | សវនាការ ពេលរសៀល២ | ចំនួនម៉ោង សរុប |
|---|---|---|---|---|---|
| ថ្ងៃចន្ទ ១០/០៦/១៣ | ៩:០៦-១០:៣១ | ១០:៥១-១១:៥៩ | ១៣:៤៥-១៤:៤៨ | ១៥:១៤-១៦:០០ | ៤ ម៉ោង និង ២២ នាទី |
| ថ្ងៃអង្គារ ១១/០៦/១៣ | ៩:០៤-១០:៣០ | ១០:៥១-១២:០០ | ១៣:៣២-១៤:៤០ | ១៥:០២-១៦:១២ | ៤ ម៉ោង និង ៥៣ នាទី |
| ថ្ងៃពុធ ១២/០៦/១៣ | ៩:០២-១០:៥៣ | ១១:២១-១២:០៥ | ១៣:៣២-១៤:៤០ | ១៥:០០-១៦:០៦ | ៤ ម៉ោង និង ៤៩នាទី |
| ថ្ងៃព្រហស្បតិ៍ ១៣/០៦/១៣ | ៩:០៦ -១០:៤៧ | ១១:០៦-១២:១៦ | ១៣:៣១-១៤:៥៤ | ១៥:១៣-១៥:៥៤ | ៤ ម៉ោង និង ៥៥ នាទី |

*រយៈពេលសវនាការជាមធ្យម* *៤ ម៉ោង និង ៤៥នាទី*

*រយៈពេលសវនាការសរុបក្នុងសប្តាហ៍នេះ* *១៨ ម៉ោង និង ៥៩ នាទី*

*ចំនួនម៉ោង ថ្ងៃ និងសប្តាហ៍នៃសវនាការ* *៨៣៤ ម៉ោង និង ១៨ នាទី*

*រយៈពេលសវនាការចំនួន ១៨៨ ថ្ងៃ អំឡុងពេល ៥៨សប្តាហ៍*

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

EAST-WEST CENTER

AIJI TRIAL MONITORING

WAR CRIMES STUDIES CENTER
UNIVERSITY OF CALIFORNIA, BERKELEY

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of KRT TRIAL MONITORwas authored by Stephanie Fung, Melanie Hyde, Anne Lang, John Reiss, Kimsan Soy, and Penelope, Van Tuyl as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East West Center and the War Crimes Studies Center.

[1] Trial Chamber. Transcript of Trial Proceedings (11 June 2013). E1/149.1 [hereinafter **11 June Transcript**]. Lines 16-17. 28.

[2] Tun Soeun was examined in the following order: President Nil Nonn; National Co-Lawyer for Khieu Samphan\ Kong Sam Onn; International Prosecutor Keith Raynor; National Civil Party Lead Co-Lawyer Pich Ang.

[3] So Socheat was examined in the following order: President of the Trial Chamber Nil Nonn; International Co-Lawyer for Khieu Samphan Arthur Vercken; Judge Jean-Marc Lavergne; International Prosecutor Keith Raynor; National Civil Party Co-Lawyer Hong Kim Suon; International Civil Party Lead Co-Lawyer Elisabeth Simonneau Fort.

[4] For example, during questioning by Prosecutor Keith Raynor, the Witness was noted to provide the following inconsistent testimony: the Witness denied being the head of the kitchen at K-1 but later admitted it after being presented with an excerpt from Khieu Samphan's book; the Witness provided inconsistent facts regarding the birth date of her son; and the Witness admitted to having discussed the disappearance of "Doeun" with Khieu Samphan despite denying it earlier.

[5] Sim Hao was examined in the following order: President Nil Nonn; International Prosecutor Vincent de Wilde d'Estmael; National Civil Party Co-Lawyer Chet Vanly; International Civil Party Co-Lawyer Christine Martineau; Judge Jean-Marc Lavergne; National Co-Lawyer for Khieu Samphan Kong Sam Onn; International Co-Lawyer for Khieu Samphan Arthur Vercken; International Co-Lawyer for Nuon Chea Victor Koppe.

[6] IR 38. Misconduct of a Lawyer states: "1. The Co-Investigating Judges or the Chambers may, after a warning, impose sanctions against or refuse audience to a lawyer if, in their opinion, his or her conduct is considered offensive or abusive, obstructs the proceedings, amounts to abuse of process, or is otherwise contrary to Article 21(3) of the Agreement. 2. The Co-Investigating Judges or the Chambers may also refer such misconduct to them appropriate professional body. 3. Any foreign lawyer practising before the ECCC who is subject to disciplinary action by the BAKC may appeal to the Pre-Trial Chamber within 15 (fifteen) days of receiving notification of the decision of the BAKC. Such appeal shall suspend enforcement of the decision unless the Pre-Trial Chamber decides otherwise. The decision of the Pre-Trial Chamber shall not be subject to appeal. 4. Where, as a result of any such disciplinary action, a person is struck off the list of lawyers approved to appear before the ECCC, the lawyer shall transmit all related material to the appropriate unit within the Office of Administration, so that it may ensure continuity of representation."

[7] *See* Case 002 KRT Trial Monitor. Issue No. 62. Hearing on Evidence Week 57 (3- 7June 2013)

[8] IR 29 states: "3. The Co-Investigating Judges and the Chambers may, on their own motion or on request, and after having consulted with the Victims Support Section or the Witnesses/Experts Support Unit, order appropriate measures to protect victims and witnesses whose appearance before them is liable to place their life or health or that of their family members or close relatives in serious danger. The Co-Investigating Judges or the Chambers may issue such an order on their own motion where there are indications in the case file of such risk. Protective measures for victims shall be requested no later than 15 days after the indictment becomes final. Protective measures for witnesses shall be requested no later than the date for the filing of the witness list referred to in Rule 80. On an exceptional basis, late applications may be considered by the Chamber. 4. In this respect, the Co-Investigating Judges and the Chambers may make a reasoned order adopting measures to protect the identity of such persons, including: a) declaring their contact address to be that of their lawyers or their Victims' Association, as appropriate, or of the ECCC; b) using a pseudonym when referring to the protected person…"

[9] IR 23.1 states: "1. The purpose of Civil Party action before the ECCC is to: a) Participate in criminal proceedings against those responsible for crimes within the jurisdiction of the ECCC by supporting the prosecution; and b? Seek collective and moral reparations, as provided in Rule 23*quinquies*."

[10] The President previously confirmed the limited role of the Duty Counsel pursuant to IR 28.9 during the testimony of Oeun Tan who had sought to consult with the Duty Counsel because he was having difficulty answering questions. *See* Case 002 KRT Trial Monitor. Issue No. 26. Hearing on Evidence Week 21 (11-14 June 2013).

[11] IR 38. Misconduct of a Lawyer states: "1. The Co-Investigating Judges or the Chambers may, after a warning, impose sanctions against or refuse audience to a lawyer if, in their opinion, his or her conduct is considered offensive or abusive, obstructs the proceedings, amounts to abuse of process, or is otherwise contrary to Article 21(3) of the Agreement. 2. The Co-Investigating Judges or the Chambers may also refer such misconduct to the appropriate professional body. 3. Any foreign lawyer practicing before the ECCC who is subject to disciplinary action by the BAKC may appeal to the Pre-Trial Chamber within 15 (fifteen) days of receiving notification of the decision of the BAKC. Such appeal shall suspend enforcement of the decision unless the Pre-Trial Chamber decides otherwise. The decision of the Pre-Trial Chamber shall not be subject to appeal. 4. Where, as a result of any such disciplinary action, a person is struck off the list of lawyers approved to appear before the ECCC, the lawyer shall transmit all related material to the appropriate unit within the Office of Administration, so that it may ensure continuity of representation."

[12] Khieu Samphan Defense. "Mr Khieu Samphan's Motion Reasserting His Right to a Fair and Adversarial Trial" (11 February 2013). Document E263.

[13] International counsel for Nuon Chea, Mr. Arthur Vercken, referred to the Trial Chamber's comments made 19 October 2012 stating, "[W]e cannot assess the weight and probative value of the documents and evidentiary material. The parties will be limited in talking about these documents because this will wait for the end of the trial."

[14] Khieu Samphan Defense. "Mr Khieu Samphan's Motion Reasserting His Right to a Fair and Adversarial Trial" (11 February 2013). Document E263. Para 11.

[15] IR 90 states: "1. The President of the Chamber shall inform the Accused of his or her rights under Rule 21(1)(d) and shall conduct the hearing. The judges have a duty to raise all pertinent questions, whether these would tend to prove or disprove the guilt of the Accused. 2. The Co-Prosecutors and all the other parties and their lawyers shall also have the right to question the Accused. All questions shall be asked with the permission of the President. Except for questions asked by the Co-Prosecutors and the lawyers, all questions shall be asked through the President of the Chamber and in the order as determined by him.

[16] The Office of the Co-Prosecutors. "Co-Prosecutors' Notification of the Time Required to Question the Accused" (6 June 2013), Document E288; and Trial Chamber. "Trial Chamber Memorandum – Further Notification of Modalities for Closing Briefs" (26 November 2012) Document E163/5/4.